**នៅចំពោះមុខ អង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦០)

ភាគីដាក់ឯកសារ៖ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 31-Mar-2020, 08:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អ.ប.ជ៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំវិធានការចាំបាច់នានារបស់ អង្គបុរេជំនុំជម្រះ ដើម្បីការពារសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/០២**

---

ដាក់ដោយ៖

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ហុង គឹមសួន
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន

Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Nushin SARKARATI

នៅចំពោះមុខ៖

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម BAIK Kang Jin
ចៅក្រម ហួត វុទ្ធី

ផ្ញើជូន៖

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា**

ជា លាង

Brenda HOLLIS

**សហមេធាវីការពារក្តី អោ អាន**

មុំ លុដ្ឋ

Richard ROGERS
Göran SLUITER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី

គីម ម៉េងឃី

ទី ស្រ៊ីនណា

វ៉េន ពៅ

Laure DESFORGE
Isabelle DURAND
Lyma NGUYEN

## សេចក្តីផ្តើម

1. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០៤/២ សូមស្នើសុំដោយសេចក្តីគោរពដល់អង្គបុរេជំនុំជម្រះ មាត្រាពិចារណាជាការបន្ទាន់អំពីសិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការពិភាក្សាសម្រេចរបស់អង្គជំនុំជម្រះ បន្ទាប់ពីការចេញអនុស្សរណៈរបស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ("អនុស្សរណៈថ្ងៃទី១២ ខែមីនា")[1] និងអនុស្សរណៈរបស់ចៅក្រមប្រធានអង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ("អនុស្សរណៈថ្ងៃទី១៦ ខែមីនា") ក្នុងនាមខ្លួនគាត់ផ្ទាល់[2]។

2. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានកាតព្វកិច្ចលើកឡើងពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ និងម្តងហើយម្តងទៀត ទៅលើសិទ្ធិក្នុងការទទួលបានសវនាការរបស់ដើមបណ្តឹងរដ្ឋប្បវេណី សិទ្ធិក្នុងការទទួលបានតំណាង សិទ្ធិទទួលបានសច្ចភាពគតិយុត្តិ និងសិទ្ធិទទួលបានតម្លាភាព និងភាពជាសាធារណៈនៃកិច្ចដំណើរការនីតិវិធីទាំងអស់នេះ។ ការរំលោភបំពានទៅលើសិទ្ធិទាំងអស់នេះនឹងត្រូវពន្យល់បកស្រាយនៅផ្នែកខាងក្រោម។

3. ទោះបីជាមានវិធានគតិយុត្តិច្បាស់លាស់ និងគួរឲ្យទុកចិត្តបាន ដែលចែងកំណត់អំពីការបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ រួមជាមួយសំណុំរឿង០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូង ក្នុងករណីមិនមានសេចក្តីសម្រេចដែលមានសម្លេងភាគច្រើនលើសលប់ដោយអង្គបុរេជំនុំជម្រះក្តី ប៉ុន្តែការិយាល័យរដ្ឋបាលមិនទាន់អនុវត្តវិធានការរដ្ឋបាលចាំបាច់នៅឡើយទេ។ ជាលទ្ធផល សំណុំរឿង ០០៤/២ បានជាប់គាំងផ្នែកនីតិវិធីនៅចន្លោះរវាងអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង ដោយមិនមានមធ្យោបាយច្បាស់លាស់ក្នុងការស្វែងរកដំណោះស្រាយ។ នេះគឺជាកាលៈទេសៈដែលបង្កព្យសនកម្មធ្ងន់ធ្ងរដល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

---

[1] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក ("សំណុំរឿង ០០៤/២") ឯកសារ D359/31.1.2 អនុស្សរណៈអន្តរការិយាល័យ ដែលចេញដោយចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ កម្មវត្ថុ៖ ការផ្ទេរសំណុំរឿង០០៤/២ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។

[2] សំណុំរឿង ០០៤/២ ឯកសារ D359/31.1.1 អនុស្សរណៈអន្តរការិយាល័យ ដែលចេញដោយចៅក្រម ប្រាក់ គឹមសាន ចៅក្រមប្រធានអង្គបុរេជំនុំជម្រះ កម្មវត្ថុ៖ ការបញ្ជាក់ឡើងវិញលើសេចក្តីសម្រេចក្នុងសំណុំរឿង០០៤/២ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០។

4. មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសូមស្នើដោយគោរពថា ភាពមិនប្រាកដប្រជាផ្នែកនីតិវិធីជុំវិញសំណុំរឿង ០០៤/២ បានបង្កើតនូវស្ថានភាពដែលមិនអាចការពារ មិនបានគិតគូរដល់សិទ្ធិជាសារវ័ន្តរបស់ជនរងគ្រោះ។ ជាបឋម ពាក្យពេចន៍នៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក តាមការបកស្រាយផ្អែកលើគោលដៅ និងគោលបំណងនៃកិច្ចព្រមព្រៀងនោះ បានបញ្ជាក់យ៉ាងច្បាស់ថា ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចោទប្រកាន់ អោ អាន បញ្ជូនទៅជំនុំជម្រះ គួរបន្តទៅអង្គជំនុំជម្រះសាលាដំបូង បើមិនមានសេចក្ដីសម្រេចដោយសម្លេងភាគច្រើនលើសលប់ដែលសម្រេចផ្ទុយពីនេះ។ រហូតមកដល់ពេលនេះ ទោះបីជាវិធានការរដ្ឋបាលដែលចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានអនុវត្ត ដូចបានបង្ហាញនៅក្នុងអនុស្សរណៈថ្ងៃទី១២ ខែមីនា របស់ពួកគាត់ក្ដី តែការិយាល័យរដ្ឋបាលបានបដិសេធមិនអនុវត្តកិច្ចការរដ្ឋបាលក្នុងការបញ្ជូនសំណុំរឿង ០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូងឡើយ ដោយសារមិនមាន “ការបញ្ជាក់បំភ្លឺដោយសមត្ថកិច្ច” ឬ “សេចក្ដីណែនាំដែលអាចបំពេញកិច្ចបាន” ពីអង្គជំនុំជម្រះ[3]។ ជាលទ្ធផល សំណុំរឿង ០០៤/២ ត្រូវជាប់គាំងផ្នែកនីតិវិធី ដោយមានឥទ្ធិពលអាក្រក់ខ្លាំងចំពោះសិទ្ធិរបស់ជនរងគ្រោះ ដូចមានចែងក្នុងអត្ថបទគតិយុត្តិរបស់ អ.វ.ត.ក។ ទាំងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលមិនទាន់ត្រូវបានទទួលស្គាល់ នៅក្នុងសំណុំរឿងនេះនៅឡើយនោះ មិនត្រូវបានផ្ដល់ដំណឹងអំពីរាល់សារណាទាំងអស់ក្នុងសំណុំរឿង ០០៤/២ ឬត្រូវបានចម្លងជូននូវរាល់ការឆ្លើយឆ្លងគ្នាតាមសារអេឡិចត្រូនិកឡើយ ដែលធ្វើឱ្យពួកគេមិនអាចផ្ដល់ភាពជាតំណាងប្រកបដោយអត្ថន័យចំពោះដើមបណ្ដឹងរដ្ឋប្បវេណី។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសូមស្នើដល់អង្គបុរេជំនុំជម្រះមេត្តាចាត់វិធានការចាំបាច់ទាំងអស់ភ្លាមៗ ដើម្បីការពារសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដោយ៖

[3] អនុស្សរណៈអន្តរការិយាល័យ ដែលចេញដោយឯកឧត្ដម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្ដីទី និងលោក Knut ROSANHAUG អនុប្រធានការិយាល័យរដ្ឋបាល កម្មវត្ថុ៖ សំណើសុំការបញ្ជាក់បំភ្លឺ តាមវិធាន ១០(២) នៃវិធានផ្ទៃក្នុង កថាខណ្ឌ ១៣ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ (សូមមើល ឧបសម្ព័ន្ធ ៧ នៃសំណុំរឿង ០០៤/២ ឯកសារ D359/31.1.2 អនុស្សរណៈអន្តរការិយាល័យ ដែលចេញដោយចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ កម្មវត្ថុ៖ ការផ្ទេរសំណុំរឿង០០៤/២ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០)។

ក. ចេញ ឬបង្គាប់ដល់ស្ថាប័នមានសមត្ថកិច្ចរបស់ អ.វ.ត.ក ឲ្យចេញសេចក្តីប្រកាសជាសាធារណៈច្បាស់លាស់អំពីស្ថានភាពនៃសំណុំរឿង ០០៤/២ និងវិធានការបន្ទាប់ជាការរំពឹងទុក ដើម្បីដោះស្រាយភាពជាប់គាំងផ្នែកនីតិវិធីបច្ចុប្បន្ននេះ។

ខ. បង្គាប់ឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសិទ្ធិចូលពិនិត្យមើលសំណុំរឿង០០៤/២ នៅដំណាក់កាលនេះ។

គ. បង្គាប់ឲ្យភាគី អង្គជំនុំជម្រះ និងស្ថាប័នផ្សេងៗទៀតទាំងអស់របស់ អ.វ.ត.ក ផ្តល់ដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី[4] នូវរាល់ការឆ្លើយឆ្លងគ្នា និងការដាក់ឯកសារទាំងអស់កន្លងមក ទាក់ទងនឹងកិច្ចដំណើរការនីតិវិធី សំណុំរឿង០០៤/២ ដែលកន្លងមកមិនទាន់បានផ្តល់ជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងការដាក់ឯកសារ និងការទំនាក់ទំនងជាមួយអង្គជំនុំជម្រះសាលាដំបូង និង

ឃ. បង្គាប់ថា ចាប់ពីពេលនេះតទៅ ភាគី អង្គជំនុំជម្រះ និងស្ថាប័នដទៃទៀតទាំងអស់នៃ អ.វ.ត.ក ចាំបាច់ត្រូវផ្តល់ការទំនាក់ទំនង និងការដាក់ឯកសារទាំងអស់ ក្នុងកិច្ចដំណើរការនីតិវិធីទាំងអស់នៃសំណុំរឿង ០០៤/២ ជូនទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់ពេលដែល អ.វ.ត.ក បានទទួលស្គាល់ជាផ្លូវការចំពោះសហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៤/២។

## ប្រវត្តិនីតិវិធី

5. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីរម្លឹកពីប្រវត្តិនីតិវិធីដែលចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានលើកឡើងនៅក្នុងអនុស្សរណៈថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០[5] ហើយចៅក្រមប្រធាន នៅ

[4] មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ និងអន្តរជាតិទាំងអស់ ដែលតំណាងឲ្យកូនក្តីក្នុងសំណុំរឿង ០០៤/២ គឺមានឈ្មោះនៅក្នុងផ្នែក "ដាក់ដោយ" និង "ផ្ញើជូន" នៃសារណានេះ។

[5] សូមមើល សំណុំរឿង ០០៤/២ ឯកសារ D359/31.1.2 អនុស្សរណៈអន្តរការិយាល័យ ដែលចេញដោយចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ កម្មវត្ថុ៖ ការផ្ទេរសំណុំរឿង០០៤/២ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។

ក្នុងនាមខ្លួនគាត់ផ្ទាល់ បានលើកនៅក្នុងអនុស្សរណៈថ្ងៃទី១៦ ខែមីនា របស់គាត់[6] ហើយសូមសបញ្ជាក់បន្ថែមពីការវិវឌ្ឍន៍ផ្នែកនីតិវិធីដូចខាងក្រោមនេះ។

6. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរដាច់ពីគ្នា ក្នុងសំណុំរឿង ០០៤/២[7]។ សហចៅក្រមស៊ើបអង្កេតជាតិបានសម្រេចថា អោ អាន មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ ដោយសារតែគាត់មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬអ្នកទទួលខុសត្រូវខ្ពស់បំផុត ហើយបានលើកលែងការចោទប្រកាន់ប្រឆាំងនឹង អោ អាន (“ដីកាសម្រេចលើកលែងចោទប្រកាន់”)[8]។ ផ្ទុយពីនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា អ.វ.ត.ក មានយុត្តាធិការលើ អោ អាន ហើយបានចោទប្រកាន់បញ្ជូនគាត់ទៅជំនុំជម្រះពីបទចោទមួយចំនួន (“ដីកាបញ្ជូនរឿងទៅជំនុំជម្រះ”)[9]។ រួមជាមួយដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីសម្រេចលើភាពអាចទទួលយកបានជាច្រើន នៅក្នុងដីកាសម្រេចមួយផ្សេងទៀត ដែលក្នុងនោះ គាត់បានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួននៅក្នុងសំណុំរឿង ០០៤/២[10]។

---

[6] សូមមើល សំណុំរឿង ០០៤/២ ឯកសារ D359/31.1.1 អនុស្សរណៈអន្តរការិយាល័យ ដែលចេញដោយចៅក្រម ប្រាក់ គឹមសាន ចៅក្រមប្រធានអង្គបុរេជំនុំជម្រះ កម្មវត្ថុ៖ ការបញ្ជាក់ឡើងវិញលើ សេចក្តីសម្រេចក្នុងសំណុំរឿង០០៤/២ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០។

[7] សំណុំរឿង ០០៤/២ ឯកសារ **D360** ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។ សំណុំរឿង ០០៤/២ ឯកសារ D359 ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតជាតិ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[8] សំណុំរឿង ០០៤/២ ឯកសារ **D359**ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតជាតិ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[9] សំណុំរឿង ០០៤/២ ឯកសារ **D360**ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[10] សំណុំរឿង ០០៤/២ ឯកសារ D362 ដីកាសម្រេចលើភាពអាចទទួលស្គាល់ អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

7. នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួនជំទាស់នឹងដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ("បណ្តឹងឧទ្ធរណ៍លើភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី")[11]។

8. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ("សេចក្តីពិចារណា") ប៉ុន្តែមិនអាចស្វែងរកសេចក្តីសម្រេចដោយសម្លេងភាគច្រើនលើសលប់ ថាតើត្រូវតម្កល់ទុកដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាសម្រេចលើកលែងចោទប្រកាន់[12]។ ***អង្គបុរេជំនុំជម្រះមិនទាន់ចេញ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីនៅឡើយ។***

9. នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិបានផ្ញើលិខិតមួយទៅអង្គជំនុំជម្រះសាលាដំបូង ស្នើសុំពន្យារពេល ១៥ ថ្ងៃបន្ថែមលើកាលបរិច្ឆេទកំណត់ក្នុងការដាក់បញ្ជីសាក្សីរបស់ខ្លួន ហើយស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងកោះអញ្ជើញបើកកិច្ចប្រជុំរៀបចំសវនាការ[13]។ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ អោ អាន បានផ្ញើលិខិតមួយទៅអង្គជំនុំជម្រះសាលាដំបូង ស្នើសុំដល់អង្គជំនុំជម្រះឱ្យបញ្ជាក់ថា ខ្លួនមិនទាន់បានទទួលសំណុំរឿង០០៤/២ នៅឡើយ ឬជាជម្រើសមួយទៀត សុំឱ្យអង្គជំនុំជម្រះសាលាដំបូងផ្តល់គោលការណ៍ណែនាំអំពីការដាក់អញ្ញត្រកម្ម[14]។ ***ទាំងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានចម្លងជូន***

---

[11] សំណុំរឿង ០០៤/២ ឯកសារ D362/5 បណ្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេច លើភាពអាចទទួលស្គាល់ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨។

[12] សំណុំរឿង ០០៤/២ ឯកសារ D359/24 & ឯកសារ D360/33 សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

[13] សំណុំរឿង ០០៤/២ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបន្ថែមពេលវេលា ដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់គាត់ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ (មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានផ្តល់សិទ្ធិចូលពិនិត្យមើលឯកសារនេះឡើយ ហេតុដូច្នេះ ការដកស្រង់នេះ គឺផ្អែកលើជើងទំព័រ៦ ទំព័រ១ នៃ សំណុំរឿង ០០៤/២ បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០២០)។

[14] សំណុំរឿង ០០៤/២ ឯកសារ D359/27.1.1 សំណើសុំការបញ្ជាក់បំភ្លឺថា អង្គជំនុំជម្រះសាលាដំបូង មិនទាន់បានទទួលដោយស្របច្បាប់ នូវសំណុំរឿង ០០៤/០២ ឬជាជម្រើសផ្សេងទៀត សំណើរសុំបន្ថែមពេលវេលា និងគោលការណ៍ណែនាំ សម្រាប់ការដាក់អញ្ញត្រកម្ម តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ (យើងបានដឹងដោយសារតែចំណុចនេះ បង្ហាញឡើងនៅក្នុងឧបសម្ព័ន្ធ នៃឯកសារផ្សេងទៀត)។

*ឡើយពីការទំនាក់ទំនងទាំងអស់នេះ។ បើតាមអ្វីដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដឹង អង្គជំនុំជម្រះសាលាដំបូងមិនកោះអញ្ជើញបើកកិច្ចប្រជុំរៀបចំសវនាការ ឬផ្តល់គោលការណ៍ណែនាំអំពីការដាក់អញ្ញត្រកម្មទេ។*

10. ចាប់ពីពេលនោះមក សហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីការពារក្តី អោ អាន បានដាក់សារណាយ៉ាងហោចណាស់ប្រាំដងទៅអង្គជំនុំជម្រះសាលាដំបូង តាមរយៈអង្គភាពគ្រប់គ្រងតុលាការ[15]។ ទោះបីជាការដាក់សារណាទាំងអស់នេះត្រូវបានអះអាងថាចម្លងជូនទៅ “មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤/២” ក្តី តែការដាក់ទាំងអស់នេះមិនត្រូវបានបញ្ចូលទៅក្នុង Zylab ឬត្រូវបានជូនដំណឹងជាផ្លូវការ ទោះជាតាមមធ្យោបាយណាក្តី[16] ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនបានទទួលឯកសារចម្លងឡើយ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានទទួលដំណឹងនេះតាមរយៈសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានផ្ញើជូនក្រៅផ្លូវការ “ឯកសារថតចម្លង” ដោយសហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីការពារក្តី

[15] សំណុំរឿង ០០៤/២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះសំណើរបស់ អោ អាន ទាក់ទងនឹងការទទួលយកសំណុំរឿង ០០៤/២ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២០។ សំណុំរឿង ០០៤/២ បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០២០។ សំណុំរឿង ០០៤/២ សេចក្តីសង្ខេបលើអញ្ញត្រកម្មរបស់ អោ អាន តាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០។ សំណុំរឿង ០០៤/២ ការដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ អោ អាន អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ជាមួយឧបសម្ព័ន្ធ ១ សម្ងាត់ និងចម្លើយតបរបស់ អោ អាន ចំពោះការដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។ ។ សំណុំរឿង ០០៤/២ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំអង្គជំនុំជម្រះសាលាដំបូង ចាត់វិធានការដើម្បីទទួលបាន ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ អោ អាន និងសំណុំរឿង ០០៤/០២ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ (មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនទទួលបានសិទ្ធិចូលពិនិត្យមើលឯកសារនេះទេ ហេតុដូច្នេះការដកស្រង់នេះគឺផ្អែកលើ កថាខណ្ឌ ៤ និងជើងទំព័រ ១៨ នៃ សំណុំរឿង ០០៤/២ ឯកសារ D359/26 ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឲ្យចាត់វាល់វិធានការរដ្ឋបាល ដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០)។

[16] មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កត់សម្គាល់ថា ការដាក់ឯកសារជាក្រដាសដោយផ្ទាល់ គឺអាចអនុញ្ញាតទៅបាន។ សូមមើល សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ នៅចំពោះមុខ អ.វ.ត.ក (វិសោធនកម្មលើកទី៨) មាត្រា ២.១, ២.៥ ឆ្នាំ ២០០៧។

អោ អាន ប៉ុណ្ណោះ[17]។ ***មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនមានមធ្យោបាយណាមួយក្នុងការបញ្ជាក់ថាមិនមានភាគីដទៃផ្សេងទៀតបានដាក់សារណាផ្សេងក្នុងសំណុំរឿង ០០៤/២ ឡើយ។***

11. នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូងបានបញ្ជូនសាអេឡិចត្រូនិកមួយ ជូនដំណឹងដល់ចៅក្រមអង្គបុរេជំនុំជម្រះ, អោ អាន, និងសហព្រះរាជអាជ្ញាថា បើទោះបីជាអង្គជំនុំជម្រះបានដឹងអំពីសេចក្តីពិចារណាក្តី ប៉ុន្តែដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ឬ សំណុំរឿងជាមូលដ្ឋាននោះ មិនទាន់ត្រូវបានបញ្ជូនជាកិច្ចការរដ្ឋបាលមកអង្គជំនុំជម្រះសាលាដំបូងឡើយ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមិនអាចអនុវត្តកិច្ចណាមួយឡើយក្នុងសំណុំរឿង[18]។ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូងបានបញ្ជូនសារអេឡិចត្រូនិក ទៅសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី អោ អាន ដោយបញ្ជាក់ថា "អង្គជំនុំជម្រះសាលាដំបូង នៅតែមិនទាន់ទទួលបានការជូនដំណឹងជាផ្លូវការអំពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះនៅឡើយទេ។ សំណុំរឿងមិនទាន់ត្រូវបានបញ្ជូនមកអង្គជំនុំជម្រះសាលាដំបូងនៅឡើយទេ។ វាអាស្រ័យលើអង្គបុរេជំនុំជម្រះក្នុងការចាប់ផ្តើមវិធានការទាំងពីរនេះ"[19]។ ***ជាថ្មីម្តងទៀត ទាំងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានចម្លងជូននៅក្នុងការទំនាក់ទំនងទាំងអស់នេះឡើយ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនមានមធ្យោបាយក្នុងការផ្ទៀងផ្ទាត់ថាតើ ខ្លួនត្រូវបានដកចេញដែរឬអត់ ពីបញ្ជីអ្នកទទួលការទំនាក់ទំនងគ្នាផ្សេងទៀត ក្នុងសំណុំរឿង០០៤/២ ពីក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ឬពីម***

[17] សារអេឡិចត្រូនិករបស់លោកស្រី Megan HIRST សហមេធាវីនាំមុខ កម្មវត្ថុ៖ សារអេឡិចត្រូនិករបស់ អ.វ.ត.ក និងសំណុំរឿង០០៤/២ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២០ (រៀបរាប់អំពីឯកសារសំណុំរឿង ០០៤/២ ដែលបានចម្លងផ្ញើជូនសហមេធាវីនាំមុខ។ សារអេឡិចត្រូនិករបស់លោកស្រី Megan HIRST សហមេធាវីនាំមុខ កម្មវត្ថុ៖ ឯកសារថតចម្លងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូង ចាត់វិធានការដើម្បីទទួលបានដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង ០០៤/២ (អោ អាន) ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ (ឯកសារចម្លងនៃសារណានេះ មិនមានភ្ជាប់មកជាមួយសារអេឡិចត្រូនិកឡើយ ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនទទួលបានសិទ្ធិចូលពិនិត្យមើលឯកសារនេះពីព្រះរាជអាជ្ញាទេ)។

[18] សំណុំរឿង ០០៤/២ ឯកសារ D359/27.1.2 សារអេឡិចត្រូនិកពីលោក លឹម ស៊ុយហុង ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង កម្មវត្ថុ៖ ព័ត៌មាន ថ្ងៃទី២១ ខែមករា ឆ្នាំ២០២០។

[19] សំណុំរឿង ០០៤/២ ឯកសារ D359/27.1.3 សារអេឡិចត្រូនិកពីលោក លឹម ស៊ុយហុង ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង កម្មវត្ថុ៖ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ (ដោយគូសបញ្ជាក់បន្ថែមលើឯកសារច្បាប់ដើម)។

*ន្រ្តីដទៃទៀតរបស់ អ.វ.ត.ក បើទោះបីជាអនុស្សរណៈថ្ងៃទី១២ ខែមីនា របស់អង្គបុរេជំនុំជម្រះ ដូចមានរៀបរាប់លម្អិតខាងក្រោម បានបង្ហាញថា ទាំងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានដកចេញក្តី។*

12. នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់*សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឱ្យចាត់វាល់វិធានការរដ្ឋបាល ដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង* ជូនទៅអង្គបុរេជំនុំជម្រះ[20]។ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ និងថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ អោ អាន បានដាក់ចម្លើយតបចំពោះសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំចាត់វិធានការ[21] និងដាក់ *សំណើសុំការបញ្ជាក់ថា បានចាត់វិធានការរដ្ឋបាល ដែលចាំបាច់ទាំងអស់ ដើម្បីរក្សាសំណុំរឿង០០៤/០២ ទុកក្នុងបណ្ណសារ* ជូនទៅអង្គបុរេជំនុំជម្រះ[22]។ នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ការឆ្លើយតបចំពោះចម្លើយតបរបស់ អោ អាន[23]។ ការដាក់សារណាទាំងអស់នេះគឺជាការដាក់សារណាដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានទទួលជាការជូនដំណឹងជាផ្លូវការ នៅក្រោយថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

13. នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូងបានផ្ញើសារអេឡិចត្រូនិកជូនទៅចៅក្រមអង្គបុរេជំនុំជម្រះ, ការិយាល័យរដ្ឋបាល, អោ អាន, សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយយោងទៅសារអេឡិចត្រូនិករបស់អង្គជំនុំជម្រះសាលាដំបូង កាលពី

[20] សំណុំរឿង ០០៤/២ ឯកសារ ឯកសារ D359/25 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឱ្យចាត់វាល់វិធានការរដ្ឋបាល ដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០។

[21] សំណុំរឿង ០០៤/២ ឯកសារ D359/26 ចម្លើយតបទៅនឹងសំណើរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឱ្យចាត់វាល់វិធានការរដ្ឋបាល ដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។

[22] សំណុំរឿង ០០៤/២ ឯកសារ ឯកសារ D359/27 សំណើសុំការបញ្ជាក់ថា បានចាត់វិធានការរដ្ឋបាល ដែលចាំបាច់ទាំងអស់ ដើម្បីរក្សាសំណុំរឿង ០០៤/០២ ទុកក្នុងបណ្ណសារ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។

[23] សំណុំរឿង ០០៤/២ ឯកសារ D359/28 ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងសំណើរបស់ ស.ព.អ ស្នើសុំឱ្យចាត់វាល់វិធានការរដ្ឋបាលទាំងអស់ដែលចាំបាច់ ដើម្បីបញ្ជូនសំណុំរឿង០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០។

ថ្ងៃទី២១ ខែមករា និងថ្ងៃទី១០ ខែកុម្ភៈ ដែលមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមិនបានទទួល ហើយកត់សម្គាល់ថា "បញ្ហាគន្លឹះដែលបានលើកឡើង គឺត្រូវបានប្ដឹងជំទាស់ដោយ សហព្រះរាជអាជ្ញាអន្តរជាតិ នៅចំពោះមុខអង្គបុរេជំនុំជម្រះ"[24]។ ***សារអេឡិចត្រូនិកនេះក៏បានយោងផងដែរ ទៅការទំនាក់ទំនងគ្នាថ្ងៃទី១៣ ខែកុម្ភៈ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលដើមបណ្ដឹងរដ្ឋប្បវេណីមិនបានទទួល***[25]។

14. ជាការឆ្លើយតបចំពោះការព្យាយាមដាក់សារណាបន្ថែមទៀតដោយសហព្រះរាជអាជ្ញាអន្តរជាតិ អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ បានផ្ញើសារអេឡិចត្រូនិកម្ដងទៀតទៅភាគីនានា នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០២០។ ***មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីភាគច្រើន ប៉ុន្តែមិនមែនទាំងអស់ ក្នុងសំណុំរឿង ០០៤/២ ត្រូវបានចម្លងជូនក្នុងការឆ្លើយឆ្លងនេះ។***

15. នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានចេញអនុស្សរណៈអន្តរការិយាល័យ តាមរយៈសារអេឡិចត្រូនិកអំពី "ការផ្ទេរសំណុំរឿង០០៤/២" រួមជាមួយឯកសារភ្ជាប់ដែល ***មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី តែមួយរូបប៉ុណ្ណោះ ត្រូវបានចម្លងជូន***[26]។ ឯកសារភ្ជាប់បានរៀបរាប់លម្អិតអំពីវិធានការជាច្រើនដែលបានអនុវត្ត និងការទំនាក់ទំនងដែលជំទាស់គ្នាភាគច្រើន ធ្វើឡើងដោយចៅក្រម និងក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ពាក់ព័ន្ធការបញ្ជូនសំណុំរឿង ០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូង[27]។ ***មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មិនត្រូវបានចម្លងជូនពីការឆ្លើយឆ្លងគ្នាទាំងអស់នោះទេ ហើយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី នៅតែមិនបានដឹងភាគច្រើនអំពីការវិវឌ្ឍន៍ទាំងអស់នេះ រហូតដល់ពេលចេញអនុស្សរណៈថ្ងៃទី១២ ខែមីនា។***

---

[24] សារអេឡិចត្រូនិកពីលោក លឹម ស៊ុយហុង ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង កម្មវត្ថុ៖ ពាក់ព័ន្ធនឹងការទំនាក់ទំនងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០។

[25] *ដូចដើងទំព័រខាងលើ។*

[26] សំណុំរឿង ០០៤/២ ឯកសារ D359/31.1.2 អនុស្សរណៈអន្តរការិយាល័យ ដែលចេញដោយចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ កម្មវត្ថុ៖ ការផ្ទេរសំណុំរឿង០០៤/២ កថាខណ្ឌ៥-២០ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។

[27] សូមមើល ឯកសារភ្ជាប់១ ដល់៨ នៃសំណុំរឿង ០០៤/២ ឯកសារ D359/31.1.2 អនុស្សរណៈអន្តរការិយាល័យ ដែលចេញដោយចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ កម្មវត្ថុ៖ ការផ្ទេរសំណុំរឿង០០៤/២ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។

16. នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ ក្នុងនាមផ្ទាល់ខ្លួនរបស់គាត់ បានចេញអនុស្សរណៈអន្តរការិយាល័យមួយ តាមរយៈសារអេឡិចត្រូនិក ស្តីពី "ការបញ្ជាក់ឡើងវិញពីសេចក្តីសម្រេចលើសំណុំរឿង ០០៤/២"[28]។ អនុស្សរណៈថ្ងៃទី១៦ ខែមីនា បានបញ្ជាក់ថាមិនមានការតម្រូវឱ្យបំពេញកិច្ចរដ្ឋបាលបន្ថែមទៀតទេ សម្រាប់អង្គបុរេជំនុំជម្រះ។ ***មានតែមេធាវីតំណាង ដើមបណ្តឹងរដ្ឋប្បវេណី មួយចំនួនតូចប៉ុណ្ណោះ ត្រូវបានចម្លងជូន នៅក្នុងការទំនាក់ទំនងនេះ***។

## សារណា

### ក. ដើមបណ្តឹងរដ្ឋប្បវេណីគឺជាភាគី នៃកិច្ចដំណើរការនីតិវិធី ហើយចាំបាច់ត្រូវគោរពដល់សិទ្ធិរបស់ពួកគាត់

17. ដើមបណ្តឹងរដ្ឋប្បវេណីគឺជាភាគីនៃកិច្ចដំណើរការនីតិវិធី[29]។ វិធាន ២៣ស្ទួន(២) នៃវិធានផ្ទៃក្នុងចែងថា "លើកលែង និងលុះត្រា តែពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបដិសេធចោល អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចអនុវត្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីបាន"[30]។

18. មាត្រា ១២(២) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក បានចែងថា៖

> អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជា គឺជាភាគីហត្ថលេខីដែរ។ ក្នុងផលប្រយោជន៍ធានាឱ្យមានសវនាការជាសាធារណៈ ហើយដំណើរការត្រឹមត្រូវ និងទុកចិត្តបាន ត្រូវយល់ថា តំណាងរបស់រដ្ឋសមាជិកនៃអង្គការសហ

[28] សំណុំរឿង ០០៤/២ ឯកសារ D359/31.1.1 អនុស្សរណៈអន្តរការិយាល័យ ដែលចេញដោយចៅក្រម ប្រាក់ គឹមសាន ចៅក្រមប្រធានអង្គបុរេជំនុំជម្រះ កម្មវត្ថុ៖ ការបញ្ជាក់ឡើងវិញលើ សេចក្តីសម្រេចក្នុងសំណុំរឿង០០៤/២ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០។

[29] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) សទ្ទានុក្រម ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ (កំណត់និយមន័យ "ភាគី" រួមបញ្ចូលទាំងសហព្រះរាជអាជ្ញា ជនត្រូវចោទ/ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី)។

[30] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥

ប្រជាជាតិ តំណាងរបស់លោកអគ្គលេខាធិការ តំណាងបណ្ដាញពត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ នឹងអាចចូលរួមស្ដាប់ការជំនុំជម្រះក្ដីបានគ្រប់ពេលវេលាទាំងអស់។ ការលើកលែងមិនឱ្យចូលរួមស្ដាប់ការជំនុំជម្រះក្ដីនេះ តាមមាត្រា១៤ នៃអនុសញ្ញាអាចធ្វើទៅបានតែក្នុងករណីចាំបាច់បំផុត តាមយោបល់របស់អង្គជំនុំជម្រះដែលពាក់ព័ន្ធ ហើយតែនៅពេលណា ដែលការផ្សព្វផ្សាយចេញទៅនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌[31]។

19. មាត្រា ៣៤ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ចែងថា៖

អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើជាសាធារណៈ និងបើកចំហសម្រាប់តំណាងរបស់រដ្ឋបរទេស តំណាងរបស់លោកអគ្គលេខាធិការ អង្គការសហប្រជាជាតិ តំណាងបណ្ដាញព័ត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ លើកលែងតែក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះវិសាមញ្ញសម្រេចថា ត្រូវជំនុំជម្រះជាសម្ងាត់ ដោយមានមូលហេតុត្រឹមត្រូវ ដោយយោងតាមនីតិវិធីជាធរមាន ដែលការផ្សព្វផ្សាយជាសាធារណៈ ធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌[32]។

20. វិធាន ២១(១) នៃវិធានផ្ទៃក្នុងចែងថា៖

ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង ជនរងគ្រោះដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធី ប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ ស្ដី

---

[31] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដី នៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុង រយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០។

[32] ច្បាប់ស្ដីពីការបង្កើតឱ្យមាន អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

ពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង ។ ក្នុងបរិបទនេះ៖

...

គ-អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី[33]។

21. អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា សិទ្ធិដែលមានចែងក្នុងមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវអនុវត្តចំពោះដើមបណ្តឹងរដ្ឋប្បវេណី[34]។ វិធាន ១៤(១) ចែងថា "បុគ្គលរាល់រូបមានភាពស្មើគ្នាចំពោះមុខតុលាការ និងអង្គជំនុំជម្រះ។ នៅក្នុងការសម្រេចអំពីបទចោទព្រហ្មទណ្ឌណាមួយប្រឆាំងរូបគាត់ ឬអំពីសិទ្ធិ និងកាតព្វកិច្ចរបស់គាត់ ក្នុងបណ្តឹងតាមផ្លូវច្បាប់ បុគ្គលរាល់រូបត្រូវទទួលបានសិទ្ធិមានសវនាការជាសាធារណៈ និងប្រកបដោយយុត្តិធម៌ ដោយអង្គជំនុំជម្រះដែលមានសមត្ថភាព ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់"[35]។

## ខ. សិទ្ធិជាសារវ័ន្តរបស់ជនរងគ្រោះ មានចែងនៅក្នុងឯកសារគោល អ.វ.ត.ក និងច្បាប់អន្តរជាតិ ចាំបាច់ត្រូវតែជាគោលការណ៍ណែនាំសម្រាប់កិច្ចដំណើរការនីតិវិធីទាំងអស់នេះ

22. បើទោះបីជាមានតម្រូវការច្បាស់លាស់ក្នុងការផ្ទេរដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងជាមូលដ្ឋាននៃសំណុំរឿង ០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូងក្តី ប៉ុន្តែផ្នែកគ្រប់គ្រងតុលាការមិនបានអនុវត្តការផ្ទេរនេះឡើយ។ ជាលទ្ធផល សំណុំរឿង០០៤/២ ត្រូវជាប់គាំងផ្នែកនីតិវិធីរវាងអង្គ

---

[33] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩), ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥

[34] សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/អជតក ឯកសារ **F26/2/2** សេចក្តីសម្រេចលើសំណើ សុំបន្ថែមពេលវេលារបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់សួរដេញដោលសាក្សី SCW-5 កថាខណ្ឌ ៧ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ (ទទួលស្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណី "ទទួលបានសិទ្ធិក្នុងការជំនុំជម្រះ ប្រកបដោយយុត្តិធម៌ ដូចមានចែងក្នុងមាត្រា ១៤(១)" និង "មានតួនាទីជាក់លាក់ និងមានកម្រិត នៅក្នុងកិច្ចដំណើរការនីតិវិធី ដូចមានចែងក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក")។

[35] កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ លេខ 999 U.N.T.S. 171។

បុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង ដែលបានបណ្តាល និងបន្តបណ្តាលឲ្យមានព្យសនកម្ម ធ្ងន់ធ្ងរចំពោះសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

23. ការគោរពសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី គឺជាធាតុផ្សំយ៉ាងសំខាន់សម្រាប់ការបង្រួបបង្រួមជាតិ ជាគោលដៅមួយដែលបានកំណត់ថាជា "គោលការណ៍ជាសារវ័ន្តមួយក្នុងការបង្កើត អ.វ.ត.ក"[36]។ ដូចដែលអង្គបុរេជំនុំជម្រះបានទទួលស្គាល់នៅក្នុងសំណុំរឿង ០០២/០២ គោលការណ៍បង្រួបបង្រួមជាតិ "បង្ហាញដល់ចៅក្រម ក៏ដូចជា អង្គជំនុំជម្រះ នៅ អ.វ.ត.ក ឲ្យស្វែងរកការពិតស្តីពីហេតុការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាការយកចិត្តទុកដាក់ជាពិសេស និងការធានាថាមានការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្ត ដែលនេះគឺជាផ្នែកមួយនៃការបង្រួបបង្រួមជាតិ"[37]។ ទោះបីជាសំណុំរឿងត្រូវបានអនុញ្ញាតឲ្យបន្តទៅជំនុំជម្រះឬអត់ ក៏បានជះឥទ្ធិពលជាសារវ័ន្តចំពោះសិទ្ធិ និងផលប្រយោជន៍ របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើសំណុំរឿងមិនបន្តសិទ្ធិរបស់ពួកគាត់នៅចំពោះមុខ អ.វ.ត.ក ត្រូវបានរំលត់ រួមទាំងសិទ្ធិចូលរួមក្នុងគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី ដែលត្រូវបន្តទៅមុខ និងទទួលបានតំណាងសម្រាប់ផលប្រយោជន៍ផ្លូវច្បាប់របស់ពួកគាត់ សិទ្ធិទទួលបានសេចក្តីសម្រេចតាមផ្លូវតុលាការ ព្រមទាំងសិទ្ធិទទួលបានសំណងចំពោះព្យសនកម្មដែលពួកគាត់បានទទួលរងប្រសិនបើជនជាប់ចោទត្រូវបានផ្តន្ទាទោស។ ដើមបណ្តឹងរដ្ឋប្បវេណីចាំបាច់ត្រូវទទួលបានសិទ្ធិចូលរួមសវនាការអំពីបញ្ហាដែលអាចរំលត់ដល់សិទ្ធិក្នុងការចូលរួមរបស់ពួកគាត់។

24. វិធាន ២១ នៃវិធានផ្ទៃក្នុង ចែងកំណត់បន្ថែមអំពីគោលការណ៍ជាសារវ័ន្តរបស់ អ.វ.ត.ក រួមទាំងឯកសារគោលរបស់ អ.វ.ត.ក ដែលចាំបាច់ត្រូវបកស្រាយ "ការពារផលប្រយោជន៍" របស់ជនរងគ្រោះ និងដើម្បីធានាថាសិទ្ធិរបស់ពួកគាត់ ត្រូវបានគោរពនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី[38]។ ដូចគ្នានេះដែរ វិធាន ២៩ នៃវិធានផ្ទៃក្នុង ចែងថា អ.វ.ត.ក "ត្រូវធានាអំពីកិច្ចការពារដល់

---

[36] សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០២") ឯកសារ **D404/2/4**, សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦៥ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១។

[37] *ដូចជើងទំព័រខាងលើ*។

[38] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ២១ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។ សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហ

ជនរងគ្រោះ...ដែលមកបង្ហាញខ្លួន” ហើយមន្ត្រីតុលាការ “ត្រូវគិតពិចារណាដល់សេចក្តីត្រូវការរបស់ជនរងគ្រោះ” នៅពេលបំពេញតួនាទីរបស់ខ្លួន[39]។ ដោយអនុលោមតាមគោលបំណងទាំងអស់នេះ អ.វ.ត.ក បានផ្តល់យន្តការពិសេសសម្រាប់ការចូលរួមរបស់ជនរងគ្រោះ គឺបណ្តឹងរដ្ឋប្បវេណី[40]។ ចំណុចនេះត្រូវបានថ្លែងគាំទ្រដោយចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ដែលដកស្រង់សិទ្ធិជាសារវ័ន្ត ដែលមានចែងនៅក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង នៅក្នុងអនុស្សរណៈថ្ងៃទី ១២ ខែមីនា របស់ពួកគាត់ ដោយរម្លឹកថា “គ្មានសិទ្ធិណាមួយត្រូវបានរក្សាទុកឡើយ ប្រសិនបើអង្គបុរេជំនុំជម្រះមិនបញ្ជាក់អំពីលទ្ធភាពសម្រាប់ភាគីនានាអាចទទួលបានចៅក្រមដែលមានសមត្ថកិច្ច គឺអង្គជំនុំជម្រះសាលាដំបូង”[41]។

---

ចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦១ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១។

[39] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ២៩ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥

[40] សំណុំរឿង ០០២ ឯកសារ **D404/2/4**, សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៨៦ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១។។ អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ២៣(១)(ខ) ស្ទួនបី ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៥។

[41] អនុស្សរណៈអន្តរការិយាល័យ ដែលចេញដោយចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ កម្មវត្ថុ៖ ការជូនដំណឹងអំពី សេចក្តីពិចារណារបស់ អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២០ (សូមមើល ឯកសារភ្ជាប់លេខ ៦ នៃសំណុំរឿង ០០៤/២ ឯកសារ **D359/31.1.2** អនុស្សរណៈអន្តរការិយាល័យ ដែលចេញដោយចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ កម្មវត្ថុ៖ ការផ្ទេរសំណុំរឿង០០៤/២ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។ សូមមើលផងដែរ សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជតក ឯកសារ **F28** សាលដីកា កថាខណ្ឌ ៦៦១ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ (“អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទោះបីជាសំណងផ្លូវចិត្ត និងសមូហភាពមិនអាចផ្តល់ សំណងពេញលេញដល់ជនរងគ្រោះ ពីការរំលោភសិទ្ធិមនុស្សខាងរូបកាយ ឬខាងសេដ្ឋកិច្ចក្តី ក៏គោលបំណងនៃសំណងទូទៅផ្សេងទៀត ត្រូវបានបំពេញនៅចំពោះមុខ អ.វ.ត.ក ក្នុងកម្រិតដែលអាចឆ្លើយតបទៅនឹង “ការរំលោភបំពានខាងចិត្តសាស្ត្រ ផ្លូវចិត្ត និងនិមិត្តរូប”។ ករណីនេះអាចសម្រេចបានតាមរយៈ “ការផ្ទៀងផ្ទាត់អង្គហេតុ និងការបង្ហាញការពិតពេញលេញជាសាធារណៈ” ដូចដែលលើកឡើងដោយសំអាងហេតុ របស់អង្គជំនុំជម្រះនានា **តាមរយៈការចូលរួមរបស់ជនរងគ្រោះ ក្នុងកិច្ចដំណើរការនីតិវិធី** និងការទទួលស្គាល់ជាបុគ្គលនៅក្នុងសាលក្រម និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលបង្ហាញនូវការទទួលស្គាល់ជាសាធារណៈ នូវការឈឺចាប់របស់ពួកគាត់...”) (ដោយគូសបញ្ជាក់បន្ថែម”)។

25. សន្ធិសញ្ញា និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក៏មានចែងផងដែរពីកាតព្វកិច្ចការពារជនរងគ្រោះ និងផ្តល់សិទ្ធិដល់ជនរងគ្រោះ រួមទាំងសិទ្ធិទទួលបានសំណង និងទទួលបានយុត្តិធម៌។ សិទ្ធិរបស់ជនរងគ្រោះ គឺជាកម្មវត្ថុនៃសេចក្តីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិ ដែលអះអាងថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មធ្ងន់ធ្ងរមានសិទ្ធិ “ទទួលបានយុត្តិធម៌ស្មើភាព និងប្រកបដោយប្រសិទ្ធិភាព សំណងភ្លាមៗ ប្រកបដោយប្រសិទ្ធភាព និងសមស្រប ចំពោះព្យសនកម្មដែលបានទទួល និងសិទ្ធិទទួលបានព័ត៌មានពាក់ព័ន្ធនឹងការរំលោភបំពាន និងយន្តការផ្តល់សំណង”[42]។ តុលាការ និងសន្ធិសញ្ញាអន្តរជាតិដទៃទៀត រួមទាំងតុលាការព្រហ្មទណ្ឌអន្តរជាតិ បានទទួលស្គាល់ថា “សិទ្ធិជាសារវ័ន្តក្នុងការទទួលបានសំណង និងការចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងកិច្ចដំណើរការនីតិវិធី ដែលកំពុងបន្ត “គឺជាចំណុចស្នូលនៃសិទ្ធិរបស់ជនរងគ្រោះ”[43]។

---

[42] គោលការណ៍ជាមូលដ្ឋាន និងការណែនាំអំពី សិទ្ធិទទួលបានសំណង និងឧបាស្រ័យសម្រាប់ជនរងគ្រោះ ដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ កថាខណ្ឌ ១១ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៦ G.A. Res. 60/147 ឯកសារ អ.ស.ប A/RES/60/147។

[43] សេចក្តីសម្រេចលើការចូលរួម របស់ជនរងគ្រោះ នៅក្នុងកិច្ចដំណើរការនីតិវិធី ពាក់ព័ន្ធស្ថានភាពនៅក្នុងសាធារណៈរដ្ឋកេនយ៉ា លេខ ICC-01/09-24 កថាខណ្ឌ ៥ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១០។ សូមមើល លក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៦៨, ៧៥ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ១៩៩៨ លេខ 2187 U.N.T.S. 90។ សូមមើលផងដែរ អនុសញ្ញាអាមេរិក ស្តីពីសិទ្ធិមនុស្ស មាត្រា ២៥(១) ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩ លេខ 1144 U.N.T.S.123 (“បុគ្គលរាល់រូបមានសិទ្ធិទទួលបាន ឧបាស្រ័យធម្មតានិងភ្លាមៗ ឬឧបាស្រ័យមានប្រសិទ្ធិភាពដទៃផ្សេងទៀត មានសិទ្ធិទទួលបានតុលាការ ឬអង្គជំនុំជម្រះដែលមានសមត្ថកិច្ច ដើម្បីការពារចំពោះសកម្មភាព ដែលរំលោភបំពានទៅលើសិទ្ធិជាសារវ័ន្តរបស់ពួកគាត់ ដូចបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬច្បាប់រដ្ឋ ដែលពាក់ព័ន្ធ ឬដែលទទួលស្គាល់ដោយសន្ធិសញ្ញាមួយនេះ...”)។ ពិធីសារនៃធម្មនុញ្ញអាហ្វ្រិក ស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនលើការបង្កើតតុលាការអាហ្វ្រិក សម្រាប់សិទ្ធិមនុស្ស និងសិទ្ធិប្រជាជន មាត្រា ២៧(១) ថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៨ ឯកសារ OAU លេខ OAU/LEG/MIN/AFCHPR/PROT.1 កែលើកកទី ២ (ឆ្នាំ ១៩៩៧) (“ប្រសិនបើតុលាការរកឃើញថា មានការរំលោភបំពានទៅលើសិទ្ធិមនុស្ស ឬសិទ្ធិប្រជាជន តុលាការត្រូវចេញដីកាសម្រេចសមស្រប ដើម្បីផ្តល់ឧបាស្រ័យចំពោះការរំលោភបំពាននេះ រួមទាំងការទូទាត់នូវសំណង ឬការបង់សងសមស្រប។ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស មាត្រា ៨ ថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៤៨ លេខ G.A. Res. 217A (III), ឯកសារ អ.ស.ប A/810 នៅទំព័រ ៧១។កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ លេខ 999 U.N.T.S. 171។ អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការធ្វើទារុណកម្ម ឬអំពើអមនុស្សធម៌ ឬបន្ទាប់បន្ថោកយ៉ាងសាហាវយង់ឃ្នងនានា មាត្រា ១៤ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ លេខ 1465 U.N.T.S. 85។

26. ពាក្យពេចន៍ទាំងនេះ នៅពេលបកស្រាយរួមគ្នា តម្រូវឲ្យ អ.វ.ត.ក មានការប្រុងប្រយ័ត្ន ជាពិសេស ដើម្បីធានាពីការចូលរួមប្រកបដោយប្រសិទ្ធភាព និងប្រកបដោយអត្ថន័យ សម្រាប់ជនរងគ្រោះ និងការពារសិទ្ធិរបស់ពួកគាត់ ក្នុងការស្វែងរកយុត្តិធម៌ជាផ្នែកមួយនៃការព្យាយាមជារួមរបស់ជាតិក្នុងការស្វែងរកយុត្តិធម៌ និងការបង្រួបបង្រួមជាតិ។ គោលការណ៍ជាសារវ័ន្តទាំងនេះ ចាំបាច់ត្រូវជាគោលការណ៍ណែនាំចំពោះគ្រប់ភាគីទាំងអស់ នៅក្នុងគ្រប់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការ រួមទាំងនៅពេលចេញសេចក្ដីសម្រេចតាមផ្លូវតុលាការ ការដាក់ឯកសារ និងការទំនាក់ទំនងជាមួយភាគីនានា។

**គ. សិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមសវនាការ សិទ្ធិមានតំណាង សិទ្ធិទទួលបានព័ត៌មាន សិទ្ធិទទួលបានសច្ចភាពគតិយុត្ត និងសិទ្ធិទទួលបានការការពារ ចំពោះកិត្តិយស និងសុខុមាលភាព ចាំបាច់ត្រូវទទួលបានការគោរពនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក**

27. ភាពមិនប្រាកដប្រជា ដែលនៅតែបន្ត ជុំវិញស្ថានភាពនៃសំណុំរឿង ០០៤/២ និងការមិនបញ្ចូលដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការដាក់ឯកសារ និងការទំនាក់ទំនងនៅក្នុងសំណុំរឿងនេះ បានរំលោភបំពានទៅលើសិទ្ធិរបស់ជនរងគ្រោះ ក្នុងការចូលរួមសវនាការប្រកបដោយអត្ថន័យ និងរារាំងដើមបណ្ដឹងរដ្ឋប្បវេណីមិនឲ្យចូលរួមប្រកបដោយប្រសិទ្ធភាព និងប្រកបដោយអត្ថន័យ នៅក្នុងកិច្ចដំណើរការនីតិវិធី។ ភាគី និងស្ថាប័នទាំងអស់របស់ អ.វ.ត.ក ចាំបាច់ត្រូវអនុវត្តក្នុងលក្ខណៈមួយ ដែលការពារដល់កិត្តិយស និងសុខុមាលភាពរបស់ជនរងគ្រោះ និងធានាថា សិទ្ធិរបស់ជនរងគ្រោះ ត្រូវទទួលបានការគោរព។

**(១) សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ តម្រូវឲ្យអង្គបុរេជំនុំជម្រះ ចេញសេចក្ដីសម្រេចដោយមានសំអាងហេតុ និងផ្ដល់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី នូវព័ត៌មានច្បាស់លាស់ និងទាន់ពេលវេលា អំពីស្ថានភាពនៃសំណុំរឿង ០០៤/២**

28. ភាគីទាំងអស់ រួមទាំងជនរងគ្រោះ មានសិទ្ធិទទួលបានតម្លាភាព និងសច្ចភាពផ្លូវច្បាប់ នៅរាល់កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក។ តាមវិធាន ២១ នៃវិធានផ្ទៃក្នុង ឯកសារគោលរបស់ អ.វ.ត.ក ចាំបាច់ត្រូវបកស្រាយដើម្បី "ធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លា

ភាព”[44]។ នៅក្នុងតុលាការមួយនេះ និងតុលាការដទៃទៀត គោលការណ៍តម្លាភាព និងសច្ចភាពផ្លូវច្បាប់ តម្រូវថា តុលាការត្រូវចេញសេចក្តីសម្រេចដោយមានសំអាងហេតុ នៅក្នុងបញ្ហាដែលស្ថិតនៅចំពោះមុខខ្លួន[45]។ តាមបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ព្រហ្មទណ្ឌ តម្លាភាព និងសច្ចភាពផ្លូវច្បាប់ក៏គ្របដណ្តប់ផងដែរចំពោះកាតព្វកិច្ចរបស់តុលាការក្នុងការផ្តល់ព័ត៌មានដល់ជនរងគ្រោះអំពី “វិសាលភាព ពេលវេលា និងការវិវឌ្ឍន៍នៃកិច្ចដំណើរការនីតិវិធី... ជាពិសេសនៅពេលដែលពាក់ព័ន្ធជាមួយនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ” និង “ជៀសវាងការពន្យារពេលមិនចាំបាច់ នៅក្នុងការសម្រេចសេចក្តីលើរឿងក្តី”[46]។

---

[44] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ២១ នៃវិធានផ្ទៃក្នុង ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

[45] សំណុំរឿង ០០២ ឯកសារ **D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៧ -៣៨។ អង្គជំនុំជម្រះតុលាការកំពូល របស់តុលាការ ICTY បានសម្រេចថាសិទ្ធិទទួលបាន សេចក្តីសម្រេចដោយមានសំអាងហេតុ គឺជាធាតុផ្សំមួយនៃសិទ្ធិ ទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងថា ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសម្រេច ដោយមានសំអាងហេតុតែមួយគត់ ដែលអាចមានការត្រួតពិនិត្យលើបណ្តឹងឧទ្ធរណ៍ ប្រកបដោយភាពត្រឹមត្រូវ សូមមើល *រដ្ឋអាជ្ញា តទល់នឹង Momir Nikolic* សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងការផ្តន្ទាទោស ថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៦ សំណុំរឿងលេខ IT-02-60/1-A កថាខណ្ឌ ៩៦។ អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTY បានសម្រេចថា “”ជាអប្បបរមាអង្គជំនុំជម្រះសាលាដំបូង ចាំបាច់ត្រូវផ្តល់សំអាងហេតុ ដើម្បីគាំទ្រការសម្រេចរបស់អង្គជំនុំជម្រះ ទាក់ទងការពិចារណាលើអង្គសេចក្តី ពាក់ព័ន្ធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ”។ *រដ្ឋអាជ្ញា តទល់នឹង Milutinovic* និងអ្នកដទៃទៀត សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំ ប្រឆាំងសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង អនុញ្ញាតដោះលែង Nebojsa Pavkovic ជាបណ្តោះអាសន្ន ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៥ សំណុំរឿងលេខ IT-05-87-AR65.1 កថាខណ្ឌ ១១។ សូមមើលផងដែរ *រដ្ឋអាជ្ញា តទល់នឹង Lubanga* សំណុំរឿងលេខ ICC-01/04-01/06-774 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ប្រឆាំងសេចក្តីសម្រេចរបស់ អង្គបុរេជំនុំជម្រះ១ ដែលមានចំណងជើងថា “សេចក្តីសម្រេចលើកទីពីរ លើសំណើរបស់រដ្ឋអាជ្ញា និងសំណើកែសម្រួល សុំកោសលុប អនុលោមតាមវិធាន ៨១” ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ៣០ (កត់សម្គាល់ថា “មានតែផ្អែកលើមូលដ្ឋាននៃសេចក្តីសម្រេចដោយមានសំអាងហេតុប៉ុណ្ណោះ ដែលអាចមានការត្រួតពិនិត្យ លើបណ្តឹងឧទ្ធរណ៍បានត្រឹមត្រូវ”)។

[46] សេចក្តីប្រកាសលើគោលការណ៍ជាមូលដ្ឋាន នៃយុត្តិធម៌សម្រាប់ជនរងគ្រោះ ដោយឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាច កថាខណ្ឌ ៦(ក),(ង) U.N.G.A. Res. 40/34 ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ ឧបសម្ព័ន្ធ ក.១។ សូមមើលផងដែរ គោលការណ៍ជាមូលដ្ឋាន និងការណែនាំអំពី សិទ្ធិទទួលបានសំណង និងឧបាស្រ័យសម្រាប់ជនរងគ្រោះ ដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅ

29. នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះ បានរម្លឹកថា សហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវចេញសេចក្តីសម្រេចដោយមានសំអាងហេតុ លើភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីគោរពដល់គោលការណ៍ជាមូលដ្ឋាននៃនីត្យានុកូលភាព រួមទាំងតម្លាភាព និងសច្ចភាពផ្លូវច្បាប់[47]។ នៅក្នុង*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* អង្គបុរេជំនុំជម្រះបានទទួលស្គាល់ជាថ្មីម្តងទៀតពីសារៈសំខាន់នៃសច្ចភាពផ្លូវច្បាប់ ថាជា "សសរស្តម្ភមូលដ្ឋាននៃច្បាប់" មួយ[48]។ អង្គជំនុំជម្រះកត់សម្គាល់ថា រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានធានានូវគោលការណ៍សច្ចភាពផ្លូវច្បាប់ តាមរយៈនីតិវិធី "ដោះស្រាយជាស្ថាពរចំពោះ ការខ្វែងយោបល់គ្នាបែបនេះ ដើម្បីជៀសវាងការជាប់គាំងផ្នែកនីតិវិធី ដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី"[49]។ អង្គបុរេជំនុំជម្រះខ្លួនឯងផ្ទាល់បានសម្រេចថា ការចេញដីកាដំណោះស្រាយដាច់ពីគ្នា បង្កើតបានជា "ការមាក់ងាយដល់គោលការណ៍សច្ចភាពគតិយុត្តិជាមូលដ្ឋាន"[50] ហើយបង្កើតបានជា "ស្ថានភាពគតិយុត្តិដែលមិនធ្លាប់មាន" ដែលរំលោភបំពានទៅលើគោលការណ៍នានារបស់ អ.វ.ត.ក[51]។

30. ការចេញសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ មិនបានផ្តល់សច្ចភាពផ្លូវច្បាប់ចំពោះដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ទោះបីជាក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ដែលតម្រូវថា ដីកាបញ្ជូនរឿងទៅ

---

លើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរ ទៅលើច្បាប់មនុស្សធម៌អន្តរជាតិ កថាខណ្ឌ ១៤ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០០៥ U.N.G.A. Res. 60/147។

[47] សំណុំរឿង ០០២ ឯកសារ **D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៧ -៣៨។

[48] សំណុំរឿង ០០៤/២ ឯកសារ **D359/24** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦៨, ៩៥, ២០៥ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

[49] សំណុំរឿង ០០៤/២ ឯកសារ **D359/24** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១១១ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

[50] សំណុំរឿង ០០៤/២ ឯកសារ **D359/24** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣០៥ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

[51] សំណុំរឿង ០០៤/២ ឯកសារ **D359/24** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១០១ -១២៤ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

ជំនុំជម្រះក្នុងសំណុំរឿង ០៤/២ គួរបន្តទៅជំនុំជម្រះ ពេលមិនមានសេចក្តីសម្រេចដោយសម្លេងភាគច្រើនលើសលប់ ដែលសម្រេចផ្សេងពីនេះក្តី ការជំទាស់ចំពោះការណែនាំពីចៅក្រមជាតិ និងចៅក្រមអន្តរជាតិរបស់អង្គបុរេជំនុំជម្រះ ចំពោះមន្ត្រីទទួលបន្ទុកសំណុំរឿង បានបណ្តាលឲ្យមានការជាប់គាំងផ្នែកនីតិវិធី និងភាពបរាជ័យ ក្នុងការផ្ទេរសំណុំរឿង ០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូង ធ្វើឲ្យកិច្ចដំណើរការនីតិវិធីជាប់គាំងដោយប្រសិទ្ធភាព ដោយមិនមានដំណើរការច្បាស់លាស់ណាមួយសម្រាប់ដោះស្រាយភាពជាប់គាំងនេះ។ តាំងពីពេលដែលសេចក្តីពិចារណាត្រូវបានចេញ ទាំងអង្គបុរេជំនុំជម្រះ និងស្ថាប័នដទៃទៀតរបស់ អ.វ.ត.ក មិនបានចេញសេចក្តីពន្យល់ច្បាស់លាស់ជាសាធារណៈ ទាក់ទងនឹងស្ថានភាពនៃសំណុំរឿង ០០៤/២ ឬវិធីសាស្ត្រក្នុងការបន្តទៅមុខឡើយ។ អនុស្សរណៈអន្តរការិយាល័យ ដែលមានភាពប្រទាំងប្រទើសគ្នាទៀតនោះ ត្រូវបានចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ចេញនៅថ្ងៃ ទី១២ ខែមីនា ឆ្នាំ២០២០ និងដោយចៅក្រមប្រធានអង្គបុរេជំនុំជម្រះ ក្នុងនាមផ្ទាល់ខ្លួនរបស់គាត់ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ បានធ្វើឲ្យការជាប់គាំងបន្តទៅមុខទៀត។ ការមិនមានភាពច្បាស់លាស់នៅក្នុងលទ្ធផលនេះ បង្កើតបានជាការរំលោភបំពានយ៉ាងច្បាស់ទៅលើសិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ ដែលបណ្តាលឲ្យដើមបណ្តឹងរដ្ឋប្បវេណី មិនដឹងច្បាស់លាស់អំពីស្ថានភាពនៃសំណុំរឿង ០០៤/២ និងសិទ្ធិរបស់ខ្លួនក្នុងការបន្តទៅមុខ។

**(២) សិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមកិច្ចដំណើរការនីតិវិធី និងសិទ្ធិទទួលបានព័ត៌មាន តម្រូវថាអ្នកតំណាងរបស់ពួកគាត់ មានសិទ្ធិដឹងឮអំពីការដាក់ឯកសារ និងការទំនាក់ទំនង ពាក់ព័ន្ធនឹងសំណុំរឿងនេះ និងទទួលបានពេលវេលា និងធនធានគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំកិច្ចដំណើរការនីតិវិធី**

31. ជនរងគ្រោះមានសិទ្ធិជាសារវ័ន្តក្នុងការចូលរួមប្រកបដោយអត្ថន័យ និងដោយយុត្តិធម៌ នៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក[52]។ សិទ្ធិទទួលបានការប្រព្រឹត្តិដោយយុត្តិធម៌ និងស្មើភាព មានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់តុលាការ ព្រមទាំងលិខិតុបករណ៍អន្តរជាតិ

[52] សូមមើល ខាងលើ នៅត្រង់ កថាខណ្ឌ ១៧-២៦។

ដែលផ្តល់ព័ត៌មានដល់ពួកគាត់[53]។ ដើម្បីសម្របសម្រួលបន្ថែមទៀតដល់ការទទួលបានសិទ្ធិទាំងអស់នេះ វិធាន ១២, ២៣ និង ២៣ ស្ទួនពីរ នៃវិធានផ្ទៃក្នុង បានចែងអំពីភាពជាតំណាងរបស់ជនរងគ្រោះ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់នីមួយៗ នៅដំណាក់កាលមុនពេលជំនុំជម្រះ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅដំណាក់កាលជំនុំជម្រះ[54]។ វិធានផ្ទៃក្នុងចែងថា គោលបំណងនៃសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺដើម្បីធានាដល់ការរៀបចំដោយប្រសិទ្ធភាពនូវអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងដើម្បីតំណាងផលប្រយោជន៍របស់ក្រុមរួមនៃដើមបណ្តឹងរដ្ឋប្បវេណី[55]។

32. ការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ជនរងគ្រោះ អាចការពារទៅបាន ដោយការធានាថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទទួលបានព័ត៌មានពាក់ព័ន្ធទាំងអស់ នៅក្នុងពេលវេលាសមស្រប។ វិធាន ២១ នៃវិធានផ្ទៃក្នុង តម្រូវថា "អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី"[56]។ អង្គបុរេជំនុំជម្រះបានកំណត់ថា តួនាទីក្នុងការផ្តល់ព័ត៌មានដល់ជនរងគ្រោះ គឺចាំបាច់

---

[53] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ២១(១)(ក) ថ្ងៃទី១៦ ខែមករា ឆ្នាំ ២០១៥ (កំណត់ថា "ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាព រវាងសិទ្ធិរបស់ភាគីទាំងឡាយ")។ គោលការណ៍ជាមូលដ្ឋាន និងការណែនាំអំពី សិទ្ធិទទួលបានសំណង និងឧបាស្រ័យសម្រាប់ជនរងគ្រោះ ដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរ ទៅលើច្បាប់មនុស្សធម៌អន្តរជាតិ កថាខណ្ឌ ១៦ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ U.N.G.A. Res. 60/147 ឯកសារ អ.ស.ប A/RES/60/147(កំណត់ពីបទដ្ឋាននៃ "ការទទួលបានយុត្តិធម៌ ដោយស្មើភាពនិងដោយប្រសិទ្ធិភាព" សម្រាប់ជនរងគ្រោះ) ។ សេចក្តីប្រកាសលើគោលការណ៍ជាមូលដ្ឋាន នៃយុត្តិធម៌សម្រាប់ជនរងគ្រោះ ដោយឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាច កថាខណ្ឌ ៦(ក),(ង) U.N.G.A. Res. 40/34 ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ ឧបសម្ព័ន្ធ ក.១ (ប្រកាសពីសិទ្ធិផ្សេងៗជាច្រើន របស់ជនរងគ្រោះ ដែលគួរត្រូវបានគោរពនៅក្នុង កិច្ចដំណើរការនីតិវិធីតុលាការ នៅក្រោមផ្នែក "ការទទួលបានយុត្តិធម៌ និងការប្រព្រឹត្តដោយយុត្តិធម៌")។

[54] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ២៣ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

[55] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ១២ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

[56] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ២១ នៃវិធានផ្ទៃក្នុង ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។ សូមមើលផងដែរ គោលការណ៍ជាមូលដ្ឋាន និងការណែនាំអំពី សិទ្ធិទទួលបានសំណង និងឧបាស្រ័យសម្រាប់ជនរង

ត្រូវទាន់ពេលវេលា ដោយកត់សម្គាល់ថា វិធាន ២១ នៃវិធានផ្ទៃក្នុង "មិនបានទុកចន្លោះប្រហោងសម្រាប់ការបកស្រាយនោះឡើយ ដោយវិធាននេះមិនបានលើកឡើង "ឆាប់បំផុតតាមដែលអាចធ្វើទៅបាន" ឬក៏ "ក្នុងពេលណាក៏ដោយ មុនពេលបញ្ចប់កិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ""[57]។

33. ព័ត៌មានជាសាធារណៈទាក់ទងនឹងកិច្ចដំណើរការនីតិវិធីទាំងអស់នេះ មានដូចរៀបរាប់ខាងក្រោម៖

ក. នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៩ សហមេធាវីការពារក្តី អោ អាន បានថ្លែងប្រកាសទៅកាន់អ្នកសារព័ត៌មាន ដោយបង្ហាញជំហរថា អោ អាន មិនអាចជំនុំជម្រះនៅ អ.វ.ត.ក បានទេ ហើយថា កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/២ ចាំបាច់ត្រូវបិទបញ្ចប់[58]។

ខ. នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានចេញសេចក្តីប្រកាសព័ត៌មាន ថ្លែងពីទស្សនៈផ្សេងគ្នារបស់ពួកគាត់ទៅលើផលវិបាកនីតិវិធីនៃ

---

គ្រោះ ដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរ ទៅលើច្បាប់មនុស្សធម៌អន្តរជាតិ បុព្វកថា ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ U.N.G.A. Res. 60/147។ សេចក្តីប្រកាសលើគោលការណ៍ជាមូលដ្ឋាន នៃយុត្តិធម៌សម្រាប់ជនរងគ្រោះ ដោយឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាច កថាខណ្ឌ ៦(ក) U.N.G.A. Res. 40/34 ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ ឧបសម្ព័ន្ធ ក.១ (ចែងពីសិទ្ធិរបស់ជនរងគ្រោះ ដែលត្រូវទទួលបានព័ត៌មាន "អំពីតួនាទី និងវិសាលភាពរបស់ពួកគាត់ ព្រមទាំងពេលវេលានិងការវិវឌ្ឍន៍ នៃកិច្ចដំណើរការនីតិវិធី ព្រមទាំងការសម្រេចសេចក្តីលើរឿងក្តីរបស់ពួកគាត់ ជាពិសេសនៅពេលមានពាក់ព័ន្ធ ជាមួយឧក្រិដ្ឋកម្មធ្ងន់ធ្ងរ និងក្នុងករណីដែលជនរងគ្រោះ ស្នើសុំព័ត៌មានបែបនេះ")។

[57] សំណុំរឿង ០០២ ឯកសារ **D404/2/4**, សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៥២ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១។

[58] Chheng NIEM ECCC Urged to dismiss AO An's Case សារព័ត៌មាន Phnom Penh Post ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៩ អាចរកបាននៅគេហទំព័រ https://www.phnompenhpost.com/national-kr-tribunal/eccc-urged-dismiss-ao-ans-case (យោងទៅរកសេចក្តីប្រកាសព័ត៌មាន ដែលធ្វើឡើងដោយមេធាវីការពារក្តី អោ អាន ដែលមិនមានបង្ហាញលើអនឡាញ)។

សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ[59]។ សេចក្តីប្រកាសព័ត៌មានត្រូវបានផ្សព្វផ្សាយដោយសារព័ត៌មាន Phnom Penh Post[60]។

គ. នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឱ្យចាត់រាល់វិធានការរដ្ឋបាល ដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង* ទៅអង្គបុរេជំនុំជម្រះ[61]។

ឃ. នៅថ្ងៃទី១៨ ខែកុម្ភៈ និងថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ អោ អាន បានដាក់ចម្លើយតបចំពោះសំណើរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ សុំបំពេញកិច្ច[62] និង*សំណើសុំការបញ្ជាក់ថា បានចាត់វិធានការរដ្ឋបាល ដែលចាំបាច់ទាំងអស់ ដើម្បីរក្សាសំណុំរឿង ០០៤/០២ ទុកក្នុងបណ្ណសារ* ជូនទៅអង្គបុរេជំនុំជម្រះ[63]។

---

[59] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ល សេចក្តីប្រកាសរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីសំណុំរឿង ០០៤/២ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ អាចរកបាននៅគេហទំព័រ https://eccc.gov.kh/sites/default/files/media/INTERNATIONAL%20AND%20NATIONAL%20OCP%27S%20STATEMENT%2024%20DEC%202019.pdf (ចូលមើលចុងក្រោយនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០)។ សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក សេចក្តីប្រកាសព័ត៌មានរបស់ សហព្រះរាជអាជ្ញាជាតិ ស្តីពីជនត្រូវចោទ អោ អាន ក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ អាចរកបាននៅគេហទំព័រ https://eccc.gov.kh/sites/default/files/media/INTERNATIONAL%20AND%20NATIONAL%20OCP%27S%20STATEMENT%2024%20DEC%202019.pdf) (ចូលមើលចុងក្រោយនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០)។

[60] Chheng NIEM, Prosecutors divided in ECCC Case 004/02, សារព័ត៌មាន Phnom Penh Post ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ អាចរកបាននៅគេហទំព័រ https://www.phnompenhpost.com/national-kr-tribunal/prosecutors-divided-eccc-case-00402) (ចូលមើលចុងក្រោយនៅ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០)។

[61] សំណុំរឿង ០០៤/២ ឯកសារ ឯកសារ D359/25, សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឱ្យចាត់រាល់វិធានការរដ្ឋបាល ដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០។

[62] សំណុំរឿង ០០៤/២ ឯកសារ D359/26 ចម្លើយតបទៅនឹងសំណើរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឱ្យចាត់រាល់វិធានការណ៍រដ្ឋបាល ដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។

[63] សំណុំរឿង ០០៤/២ ឯកសារ ឯកសារ D359/27 សំណើសុំការបញ្ជាក់ថា បានចាត់វិធានការរដ្ឋបាល ដែលចាំបាច់ទាំងអស់ ដើម្បីរក្សាសំណុំរឿង ០០៤/០២ ទុកក្នុងបណ្ណសារ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។

ង. នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ និងថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិ បានឆ្លើយតបចំពោះចម្លើយតបរបស់ អោ អាន ទាក់ទងសំណើរបស់សហព្រះរាជអាជ្ញា និងបានដាក់ចម្លើយតប ចំពោះសំណើរបស់ អោ អាន[64]។

34. ទាំងអស់នេះគឺជាសារណាដំបូងៗ ដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានជូនដំណឹងជាផ្លូវការ នៅក្រោយថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។ ដោយសារតែមិនមានក្របខណ្ឌរដ្ឋបាលសម្រាប់ការជូនដំណឹងបែបនេះ សារណានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងមិនបានគោរពតាមលក្ខណៈតម្រូវនៃសំណុំរឿង, ប្រព័ន្ធចាត់ចំណាត់ថ្នាក់ឯកសារ ឬការជូនដំណឹងអំពីអ្នកចូលរួមក្នុងកិច្ចដំណើរការនីតិវិធី។ ការដាក់ឯកសារនៅចំពោះមុខអង្គបុរេជំនុំជម្រះ ក៏មិនបានបែងចែកត្រឹមត្រូវទៅភាគីនានាឡើយ ជាពិសេសទៅដើមបណ្តឹងរដ្ឋប្បវេណី។ ជារួម មានការគោរពតាមតិចតួចប៉ុណ្ណោះចំពោះសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ឬវិធានទូលាយនានាទាក់ទងនឹងយុត្តិធម៌បើកទូលាយ។

35. ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានបង្ហាញយ៉ាងច្បាស់តាមរយៈអនុស្សរណៈថ្ងៃទី១២ ខែមីនា ថា ពួកគាត់មិនរំពឹងថា មានសេចក្តីសម្រេចបន្ថែមទៀតរបស់អង្គបុរេជំនុំជម្រះ ដើម្បីដោះស្រាយ

[64] សំណុំរឿង ០០៤/២ ឯកសារ D359/28 ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងសំណើរបស់ ស.ព.អ ស្នើសុំឱ្យចាត់រាល់វិធានការរដ្ឋបាលទាំងអស់ដែលចាំបាច់ ដើម្បីបញ្ជូនសំណុំរឿង០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០។ សំណុំរឿង ០០៤/២ ឯកសារ D359/30 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថា វិធានការរដ្ឋបាលដែលត្រូវការទាំងអស់ ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង ០០៤/២ នៅក្នុងបណ្ណសារ ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០។ សំណុំរឿង ០០៤/២ ឯកសារ D360/37 ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងសំណើរបស់ ស.ព.អ ស្នើសុំឱ្យចាត់រាល់វិធានការរដ្ឋបាលទាំងអស់ ដែលចាំបាច់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០។ សំណុំរឿង ០០៤/២ ឯកសារ D360/39 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថា វិធានការរដ្ឋបាលដែលត្រូវការទាំងអស់ ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០។

ភាពជាប់គាំងក្នុងសំណុំរឿង០០៤/២ នាពេលអនាគតឆាប់ៗនេះឡើយ[65] ហើយគោលជំហរនេះត្រូវបានបញ្ជាក់បន្ថែមទៀត នៅក្នុងអនុស្សរណៈថ្ងៃទី១៦ ខែមីនា។

36. បន្ទាប់ពីការចេញសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ការដែលអង្គបុរេជំនុំជម្រះ ឬស្ថាប័នដទៃទៀតរបស់ អ.វ.ត.ក មិនផ្តល់ការពន្យល់អំពីស្ថានភាពនៃសំណុំរឿង ០០៤/២ នោះ បានរំលោភទៅលើសិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលបានព័ត៌មានទាក់ទងនឹងកិច្ចដំណើរការនីតិវិធីហើយ។ ការរំលោភបំពាននេះកាន់តែមានភាពធ្ងន់ធ្ងរថែមទៀត ដោយការបន្តមិនបញ្ចូលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅក្នុងការដាក់ឯកសារ និងការទំនាក់ទំនងគ្នារវាងភាគីនានា និងអង្គជំនុំជម្រះដែលកំពុងតែធ្វើឡើងនៅក្នុងសំណុំរឿងនេះ។ ស្ថានភាពនេះធ្វើឱ្យជនរងគ្រោះមិនមានលទ្ធភាពចូលរួមដោយប្រសិទ្ធភាព ឬប្រកបដោយអត្ថន័យ តាមរយៈអ្នកតំណាង គឺ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់។ ដូចដែលបានរៀបរាប់យ៉ាងលម្អិតនៅក្នុងផ្នែកប្រវត្តិនីតិវិធីរួចហើយ ការទំនាក់ទំនង និងការដាក់ឯកសារជាច្រើន មិនបានដាក់ឈ្មោះ និង/ឬមិនបានផ្ញើជូនអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីណាមួយឡើយ។ ក្នុងករណីខ្លះទៀត ការដាក់ឯកសារមានបញ្ជាក់ឈ្មោះមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងផ្នែក "ផ្ញើជូន" ប៉ុន្តែ ឯកសារមិនអាចរកឃើញនៅក្នុង Zylab ហើយក៏មិនបានផ្ញើជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែរ។ ក្នុងករណីផ្សេងទៀត សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានដាក់បញ្ចូលក្នុងការផ្ញើជូន ជំនួសឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅវិញ។

37. ស្ថានភាពកិច្ចការបច្ចុប្បន្ន ទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនមានប្រសិទ្ធភាព និងផ្ទុយទៅនឹងប្រព័ន្ធដែលបានចែងនៅក្នុងវិធានផ្ទៃក្នុង ហើយបានរំលោភបំពានទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានភាពជាតំណាងប្រកបដោយប្រសិទ្ធភាព។ ការិយាល័យរដ្ឋបាល និងអង្គបុរេជំនុំជម្រះ មិនបានទទួលស្គាល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីរបស់តុលាការតែមួយ នៅក្នុងសំណុំរឿង ០០៤/២ ដែលធ្វើឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺជាអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីតែមួយគត់ ដែលទទួលស្គាល់ដោយស្ថាប័នរបស់

---

[65] សំណុំរឿង ០០៤/២ ឯកសារ D359/31.1.2 អនុស្សរណៈអន្តរការិយាល័យ ដែលចេញដោយចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ កម្មវត្ថុ៖ ការផ្ទេរសំណុំរឿង០០៤/២ កថាខណ្ឌ ៣ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។

អ.វ.ត.ក នៅក្នុងសំណុំរឿង០០៤/២។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនមានសិទ្ធិស្វ័យប្រវត្តិក្នុងការដាក់សារណានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ ដោយសារតែមានតែសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឲ្យធ្វើបែបនេះនៅដំណាក់កាលជំនុំជម្រះ និងដំណាក់កាលបន្តបន្ទាប់[66]។ ទោះជាយ៉ាងនេះក្តី ដោយសារតែភាពច្របូកច្របល់ផ្នែកនីតិវិធី ដែលបង្កឡើងដោយសេចក្តីពិចារណា ទើបនៅក្នុងករណីខ្លះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបញ្ចូលទៅក្នុងបញ្ជីផ្ញើជូន ជំនួសឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងនៅក្នុងករណីខ្លះផ្សេងទៀត មានតែក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនតូច ត្រូវបានបញ្ចូល។

38. នៅមានករណីដទៃខ្លះទៀតដែលមិនមានការចម្លងជូនអ្នកតំណាងណាមួយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ក្នុងស្ថានភាពនេះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបង្ខំឲ្យស្វែងយល់អំពីការដាក់ឯកសារសំខាន់ៗ តាមករណីនីមួយៗ តាមរយៈព័ត៌មានដែលបានផ្តល់ជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ការពិភាក្សាក្រៅផ្លូវការជាមួយភាគីទីបី និង/ឬឧបសម្ព័ន្ធនៃការដាក់ឯកសារថ្មីៗបំផុតក្នុងសំណុំរឿង ០០៤/២។ ដោយសារតែមិនមានការទទួលស្គាល់ពីសំណាក់តុលាការចំពោះសហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៤/២ និងរហូតទាល់តែមានការប្រកាសជាផ្លូវការអំពីការទទួលស្គាល់នេះ ប្រាប់ជូនដល់ភាគីនានា ពេលនោះសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី តម្រូវថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានទទួលរាល់ការដាក់ឯកសារ និងការទំនាក់ទំនងនានា ដែលពួកគាត់មិនត្រូវបានបញ្ចូលនាពេលកន្លងមក ហើយតម្រូវថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបញ្ចូលនៅក្នុងការទំនាក់ទំនង និងការដាក់ឯកសារនានា ទាក់ទងនឹងកិច្ចដំណើរការនីតិវិធីសំណុំរឿង០០៤/២ នាពេល

---

[66] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ២៣(៣), ១២ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។ សំណុំរឿង ០០២ ឯកសារ E74 ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងសំណើសុំលេខ E67, E57, E56, E58, E23, E59, E20, E33, E71 និង E73 ក្រោយកិច្ចប្រជុំរៀបចំសវនាការ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ២ ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ (ដោយកត់សម្គាល់ថា ការផ្លាស់ប្តូរវិធានផ្ទៃក្នុង ដែលចូលជាធរមានចាប់តាំងពីសំណុំរឿង ០០១ បានអនុញ្ញាតឲ្យសហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី ទទួលតួនាទីជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែ "មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនមានសិទ្ធិស្វ័យប្រវត្តិ ក្នុងការចូលរួមនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ")។

ខាងមុខ។ ទាំងនេះគឺជាសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងនាមជាភាគីពេញសិទ្ធិមួយនៃកិច្ច ដំណើរការនីតិវិធី ហើយនេះគឺជាមធ្យោបាយតែមួយគត់ ដែលនាំឲ្យមានភាពជាតំណាង ដែលដើម បណ្តឹងរដ្ឋប្បវេណី មានសិទ្ធិទទួលបានដូចមានចែងក្នុងច្បាប់។

39. ការដែលតុលាការមិនបានទទួលស្គាល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឲ្យបាន ទាន់ពេលវេលានោះ នឹងបង្កការប៉ះពាល់បន្ថែមទៀតដល់លទ្ធភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុង ការចូលរួមប្រកបដោយអត្ថន័យ និងប្រសិទ្ធភាពនៅក្នុងកិច្ចដំណើរការនីតិវិធី។ ការបកស្រាយយ៉ាង សាមញ្ញទៅលើវិធានផ្ទៃក្នុង បង្ហាញយ៉ាងច្បាស់ថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋ ប្បវេណី មានគោលដៅដើម្បីអន្តរាគមន៍ក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង នៅពេលវេលាមួយ ដែលអនុញ្ញាតឲ្យពួកគេមានឱកាសស្មើគ្នា និងសមស្រប ក្នុងការត្រៀមរៀបចំកិច្ចដំណើរការនីតិវិធី ជំនុំជម្រះ។ នៅក្នុងន័យនេះហើយដែល វិធាន ៦៩(៣) នៃវិធានផ្ទៃក្នុងចែងថា “ការដាក់ពាក្យប្តឹង ឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ មិនរារាំងអង្គជំនុំជម្រះសាលាដំបូង និងសហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការមើលសំណុំរឿង ក្នុងគោលបំណងត្រៀមរៀបចំជាមុន សម្រាប់ការជំនុំជម្រះទេ”[67]។ បទប្បញ្ញត្តិនេះរំពឹងទុកយ៉ាងច្បាស់ពីការចូលរួមរបស់សហមេធាវីនាំ មុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការចូលពិនិត្យមើលសំណុំរឿង តាំងពីមុនពេលសំណុំ រឿង ត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង។ នេះគឺជារឿងសមហេតុផលដែលវិធានផ្ទៃក្នុង អនុញ្ញាតត្រឹម ១៥ ថ្ងៃ បន្ទាប់ពីពេលប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង សម្រាប់ឲ្យ ក.ស.ព ដាក់ បញ្ជូនសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលស្នើឡើង (វិធាន ៨០(១) នៃវិធានផ្ទៃក្នុង) ត្រឹម៣០ថ្ងៃ ក្រោយពេលប្តឹង សម្រាប់សហមេធាវីនាំមុខ ក្នុងការដាក់បញ្ជីរបស់ពួកគេ (វិធាន ៨០(២) នៃវិធានផ្ទៃក្នុង)។ អញ្ញត្រកម្មត្រូវដាក់ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីដីកាដំណោះស្រាយបាន ចូលជាស្ថាពរ។ ពេលវេលាបែបនេះប្រាកដជាខ្លីខ្លាំងណាស់សម្រាប់សហមេធាវីនាំមុខតំណាងដើម បណ្តឹងរដ្ឋប្បវេណី ប្រសិនបើពួកគាត់មិនអាចចូលពិនិត្យមើលសំណុំរឿងនាពេលកន្លងមក ដើម្បី ជំរុញដល់ការត្រៀមរៀបចំ អនុលោមតាមវិធាន ៦៩(៣) នៃវិធានផ្ទៃក្នុង។

[67] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ៦៩ នៃវិធានផ្ទៃក្នុង ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

40. បញ្ហានៃការពន្យារកិច្ចអន្តរាគមន៍របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបង្ហាញច្បាស់នៅដំណាក់កាលនេះ ក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង០០៤/២។ សហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីការពារក្តី អោ អាន បានដាក់បញ្ជីសាក្សី និងអ្នកជំនាញ ព្រមទាំងអញ្ញត្រកម្ម តាមវិធាន ៨០ នៃវិធានផ្ទៃក្នុងរួចទៅហើយ[68] ដែលនេះជាការងារដែល សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងដោយសារហេតុផលជាក់ស្តែង និងហេតុផលផ្លូវច្បាប់ តម្រូវឲ្យមានការដឹកនាំ ការសម្របសម្រួល និងធនធាន តាមរយៈការិយាល័យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ដូចដែលបានកត់សម្គាល់ពីខាងលើ មានការយល់ច្រឡំខ្លាំងក្នុងចំណោមភាគី ថាតើមេធាវីរូបណា ដែលត្រូវសម្របសម្រួលភាពជាតំណាងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី នៅដំណាក់កាលនេះ ដែលបណ្តាលឲ្យភាគីធ្វើការចម្លងជូនការដាក់ឯកសារ និងការទំនាក់ទំនងនានាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនចម្លងជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបណ្តាលឲ្យដើមបណ្តឹងរដ្ឋប្បវេណីមិនមានភាពជាអ្នកតំណាងផ្លូវច្បាប់ ដែលជាការជំរុញជាគន្លឹះដល់កិច្ចដំណើរការនីតិវិធី ឲ្យកើតមាន។ ប្រាកដណាស់ថា នៅពេលវេលាមួយដែលកិច្ចដំណើរការនីតិវិធី បានចាប់ផ្តើមឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នឹងចាំបាច់ត្រូវស្នើសុំការពន្យារពេល ប្រសិនបើពួកគាត់មិនទទួលបានឱកាសក្នុងការស្វែងយល់ឲ្យច្បាស់លាស់អំពីសំណុំរឿងជាមុនទេ។

41. ក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីបានដឹងអំពីការដាក់ឯកសារ ទៅអង្គជំនុំជម្រះសាលាដំបូង ហើយចង់ដាក់ចម្លើយតបរបស់ខ្លួន វិធានផ្ទៃក្នុងបានរារាំងពួកគាត់មិនឲ្យដាក់ឡើយ ដោយសារតែមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនមានសិទ្ធិនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (ហើយតុលាការមិនបានទទួលស្គាល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបច្ចុប្បន្ន នៅក្នុង

---

[68] សំណុំរឿង ០០៤/២ បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០២០។ សំណុំរឿង ០០៤/២ សេចក្តីសង្ខេបលើអញ្ញត្រកម្មរបស់ អោ អាន តាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០។ សំណុំរឿង ០០៤/២ ការដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ អោ អាន អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ជាមួយឧបសម្ព័ន្ធ ១ សម្ងាត់ និងចម្លើយតបរបស់ អោ អាន ចំពោះការដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។

សំណុំរឿង ០០៤/២ ឡើយ)។ កាលៈទេសៈបែបនេះបានធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីមានគុណវិបត្តិខ្លាំង ធៀបទៅនឹងភាគីដទៃទៀត ដែលបានចាប់ផ្តើមការត្រៀមរៀបចំសវនាការ តាំងពីបីខែមុនមកម្ល៉េះ។ ស្ថានភាពនេះក៏បានរំលោភបំពានទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមប្រកបដោយអត្ថន័យ និងប្រសិទ្ធភាព នៅក្នុងកិច្ចដំណើរការនីតិវិធី សិទ្ធិទទួលបានភាពស្មើគ្នា និងសិទ្ធិទទួលបានតុល្យភាពនៃផលប្រយោជន៍ ធៀបទៅនឹងភាគីដទៃទៀតនៃកិច្ចដំណើរការនីតិវិធី។

42. ដើម្បីធានាថា ការរំលោភបំពានទាំងអស់នេះ លែងកើតមានបន្តទៀត ដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើឱ្យអង្គបុរេជំនុំជម្រះមេត្តាបង្គាប់ដល់ភាគីនានាឱ្យផ្ញើជូនរាល់ការទំនាក់ទំនង និងការដាក់ឯកសារនានា ទាក់ទងនឹងកិច្ចដំណើរការនីតិវិធី សំណុំរឿង០០៤/២ ទាំងពេលបច្ចុប្បន្ន និងពេលកន្លងមក ទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងនេះ រហូតដល់ពេលដែលតុលាការបានទទួលស្គាល់ជាផ្លូវការចំពោះសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤/២ ហើយផ្តល់ដល់ពួកគាត់នូវសិទ្ធិចូលពិនិត្យមើលសំណុំរឿង អនុលោមតាមវិធាន ៦៩(៣) នៃវិធានផ្ទៃក្នុង។ មានតែវិធានការនេះទេ ដែលអាចធានាបានថា ដើមបណ្តឹងរដ្ឋប្បវេណីអាចចាប់ផ្តើមការត្រៀមរៀបចំ សម្រាប់ការជំនុំជម្រះ ក្រោមការសម្របសម្រួលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**(៣) ភារកិច្ចរបស់តុលាការក្នុងការការពារកិត្តិយស និងសុខុមាលភាពជនរងគ្រោះ ដែលចូលរួមក្នុងកិច្ចដំណើរការនីតិវិធី តម្រូវថា តុលាការត្រូវអនុញ្ញាតតាមសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

43. នេះជាគោលការណ៍ជាសារវន្តនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដែលថា ផលប្រយោជន៍របស់ជនរងគ្រោះ ត្រូវបានការពារ[69]។ ការសម្របសម្រួលរបបនៃការចូលរួមរបស់ជនរងគ្រោះនៅ អ.វ.ត.ក គឺជាគោលការណ៍ច្បាប់អន្តរជាតិ ដែលទទួលស្គាល់ និងឆ្លើយតបចំពោះភាពងាយទទួលរងគ្រោះ និងការប៉ះទង្គិច ដែលជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងអំពើសាហាវយង់ឃ្នងជាទ្រង់ទ្រាយធំ បានទទួលរង ហើយមានចេតនាដើម្បីរារាំងព្យសនកម្មចំពោះជនរងគ្រោះ ដែលព្យសនកម្មនោះ ជាផលវិបាកនៃការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការយុត្តិធម៌។ និយាម

---

[69] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិធាន ២១ នៃវិធានផ្ទៃក្នុង ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

អន្តរជាតិដែលគ្រប់គ្រងលើដំណើរការតុលាការ បានអំពាវនាវឱ្យប្រព្រឹត្តចំពោះជនរងគ្រោះដោយយកចិត្តទុកដាក់ ដោយមេត្តា និងគោរពចំពោះកិត្តិយសរបស់ជនរងគ្រោះ ដែលពួកគាត់ត្រូវទទួលបានការយកចិត្តទុកដាក់ និងការថែទាំជាពិសេស ដើម្បីកុំឱ្យពួកគាត់ជួបប្រទះការប៉ះទង្គិចសារជាថ្មី និងដើម្បីការពារពួកគាត់ឱ្យរួចពីព្យសនកម្មរូបរាងកាយ និងផ្លូវចិត្ត[70]។

44. ដូចដែលបានរៀបរាប់លម្អិតនៅក្នុងសារណានេះ ឧបសគ្គចំពោះការចូលរួមរបស់ជនរងគ្រោះប្រកបដោយអត្ថន័យ និងប្រសិទ្ធភាព គឺ ការចែករំលែកព័ត៌មានមិនបានគ្រប់គ្រាន់ជាមួយជនរងគ្រោះ ព្រមទាំងការមិនមានតម្លាភាព និងសច្ចភាពផ្លូវច្បាប់ ដែលស្ថិតនៅក្នុងការជាប់គាំង ដែលកំពុងតែបន្តក្នុងសំណុំរឿង ០០៤/២ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដែលបណ្ដាលឱ្យមានព្យសនកម្មចំពោះជនរងគ្រោះ ជារៀងរហូត និងមិនអាចអនុញ្ញាតបាន។ ប្រសិនបើអនុញ្ញាតឱ្យបន្តទៅទៀត កាលៈទេសៈទាំងអស់នេនឹងមិនគ្រាន់តែបង្កើតឱ្យមានការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ និងជាបន្តចំពោះសិទ្ធិរបស់ជនរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កហានិភ័យនៃការប៉ះទង្គិចសារជាថ្មីចំពោះជនរងគ្រោះ ដែលធ្វើឱ្យប៉ះពាល់ដល់ជំនឿ និងការទុកចិត្តរបស់ពួកគាត់ នៅក្នុងដំណើរការរបស់តុលាការ និងបង្កបញ្ហាដល់ការចូលរួមចំណែកក្នុងការបង្រួបបង្រួមជាតិ ដែល អ.វ.ត.ក អាចអនុវត្ត ហើយ ***បញ្ជូនសារ ដែលមានលក្ខណៈមិនល្អខ្លាំងថា តុលាការមិនគោរពសិទ្ធិរបស់ជនរងគ្រោះ មិនផ្ដល់តម្លៃដល់ការចូលរួមរបស់ជនរងគ្រោះ ឬមិនយល់អំពីការឈឺចាប់របស់ជនរងគ្រោះ***។

45. អង្គបុរេជំនុំជម្រះបានសិទ្ធិអំណាចក្នុងការបន្ធូរបន្ថយ ឬជៀសវាងការធ្វើឱ្យមានព្យសនកម្មដែលមិនចាំបាច់ទាំងអស់នេះ ចំពោះជនរងគ្រោះ តាមរយៈការអនុញ្ញាតតាមសំណើនៅក្នុងសារណានេះ ហើយអនុវត្តភ្លាមៗទៅតាមសំណើនោះ។

---

[70] សូមមើល គោលការណ៍ជាមូលដ្ឋាន និងការណែនាំអំពី សិទ្ធិទទួលបានសំណង និងឧបាស្រ័យសម្រាប់ជនរងគ្រោះ ដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរ ទៅលើច្បាប់មនុស្សធម៌អន្តរជាតិ កថាខណ្ឌ ១០ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ U.N.G.A. Res. 60/147។ សេចក្តីប្រកាសលើគោលការណ៍ជាមូលដ្ឋាន នៃយុត្តិធម៌សម្រាប់ជនរងគ្រោះ ដោយឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាច កថាខណ្ឌ ៦(ក),(ង) U.N.G.A. Res. 40/34 ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ១៩៨៥ ឧបសម្ព័ន្ធ ក.១។ លក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៦៨, ៧៥ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ១៩៩៨ 2187 U.N.T.S. 90។

## ឃ. អនុលោមតាមក្របខណ្ឌ អ.វ.ត.ក ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២ គួរតែបន្តទៅជំនុំជម្រះ

46. ដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រដល់គោលជំហរដែលសហព្រះរាជអាជ្ញាអន្តរជាតិបានពន្យល់ក្នុងសារណារបស់គាត់ ដែលលើកទឡ្ហីករណ៍ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២ មានអានុភាព ហើយជំរុញឱ្យអង្គជំនុំជម្រះសាលាដំបូង ផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីដោយប្រញាប់[71]។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចូលដោយធ្វើការយោង និងតាមរយៈឧបសម្ព័ន្ធ ១ និង២ នៃសារណានេះ ចំពោះសារណាផ្ទាល់របស់ពួកគាត់ អំពីបញ្ហានេះ ដូចបានលើកឡើងរួចហើយនៅក្នុងសំណុំរឿង០០៤ ប៉ុន្តែមូលដ្ឋានគតិយុត្តិ និងទឡ្ហីករណ៍ អាចអនុវត្តបានដូចគ្នាក្នុងសំណុំរឿងនេះ គឺសំណុំរឿង ០០៤/២[72]។ ដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់ព័ត៌មានបន្ថែមលើបញ្ហានេះ នៅចំពោះ

---

[71] សូមមើល សំណុំរឿង ០០៤/២ ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (ឯកសារ D359), កថាខណ្ឌ ១០០-១០៨, ១១២ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨។ សំណុំរឿង ០០៤/២ ឯកសារ **D360/9** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាសម្រេច បញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៥-១៥, ១២០ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩។ សំណុំរឿង ០០៤/២ ឯកសារ ឯកសារ **D359/25**, សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឱ្យចាត់វាល់វិធានការរដ្ឋបាល ដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០។ សំណុំរឿង ០០៤/២ ឯកសារ **D360/34** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឱ្យចាត់វាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០។ សំណុំរឿង ០០៤/២ ឯកសារ **D359/28** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងសំណើរបស់ ស.ព.អ ស្នើសុំឱ្យចាត់វាល់វិធានការរដ្ឋបាលទាំងអស់ដែលចាំបាច់ ដើម្បីបញ្ជូនសំណុំរឿង០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០។ សំណុំរឿង ០០៤/២ ឯកសារ **D360/37** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងសំណើរបស់ ស.ព.អ ស្នើសុំឱ្យចាត់វាល់វិធានការរដ្ឋបាលទាំងអស់ ដែលចាំបាច់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០។ សំណុំរឿង ០០៤/២ ឯកសារ **D359/30** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថា វិធានការរដ្ឋបាលដែលត្រូវការទាំងអស់ ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង ០០៤/២ នៅក្នុងបណ្ណសារ ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០។ ។ សំណុំរឿង ០០៤/២ ឯកសារ **D360/39**, ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថា វិធានការរដ្ឋបាលដែលត្រូវការទាំងអស់ ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០។

[72] សំណុំរឿង ០០៤/០៧-០៩-២០០៩-អវតក/កសចស ឯកសារ **D381/20** បណ្តឹងឧទ្ធរណ៍របស់សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតជាតិ ក្នុងសំណុំរឿង ០០៤ ថ្ងៃទី៦ ខែធ្នូ ឆ្នាំ

មុខអង្គបុរេជំនុំជម្រះ ឬស្ថាប័នតុលាការដទៃទៀតរបស់ អ.វ.ត.ក ក្នុងករណីមានការស្នើសុំ រួមទាំងពីការិយាល័យចៅក្រមស៊ើបអង្កេត និង/ឬអង្គជំនុំជម្រះសាលាដំបូង។

## សេចក្តីសន្និដ្ឋាន

47. សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានតម្លាភាព សច្ចភាពផ្លូវច្បាប់ ការចូលរួម ការប្រព្រឹត្តិដោយយុត្តិធម៌ និងស្មើភាពគ្នា និងការការពារកិត្តិយស និងសុខុមាសភាពរបស់ពួកគាត់ ចាំបាច់ត្រូវតែគោរពនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។ សិទ្ធិទាំងអស់នេះមានចែងនៅក្នុង ឯកសារជាសារវ័ន្តរបស់ អ.វ.ត.ក ហើយត្រូវបានគាំទ្រដោយលិខិតុបករណ៍អន្តរជាតិ ស្តីពីការប្រព្រឹត្តិចំពោះជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការរំលោភបំពានសិទ្ធិមនុស្ស។

48. ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងរួចហើយ អ.វ.ត.ក ចាំបាច់ត្រូវតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង ក្នុងករណីមិនមានសេចក្តីសម្រេចដោយសម្លេងភាគច្រើនលើសលប់របស់អង្គបុរេជំនុំជម្រះ សម្រេចលើកលែងការចោទប្រកាន់។ បទដ្ឋាននេះត្រូវបង្ហាញច្បាស់ដោយអត្ថន័យធម្មតានៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គោលដៅ និងគោលបំណងរបស់តុលាការ ក្នុងការជំនុំជម្រះសេចក្តីលើអំពើសាហាវយង់ឃ្នង់ជាទ្រង់ទ្រាយធំនៃរបបខ្មែរក្រហម និងគោលការណ៍ច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដែលសង្កត់ធ្ងន់ទៅលើសិទ្ធិរបស់ជនរងគ្រោះ និងភារកិច្ចក្នុងការជំនុំជម្រះ។

49. អាស្រ័យហេតុនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើដល់អង្គបុរេជំនុំជម្រះមេត្តា ៖

ក. ចេញសេចក្តីថ្លែងការណ៍សាធារណៈ ឬបង្គាប់ឲ្យស្ថាប័នមានសមត្ថកិច្ចរបស់ អ.វ.ត.ក ចេញសេចក្តីថ្លែងការណ៍ជាសាធារណៈ ស្តីពីស្ថានភាពនៃសំណុំរឿង ០០៤/២ និងជំហានជាបន្ទាប់ដែលរំពឹងទុក ដើម្បីដោះស្រាយភាពជាប់គាំងផ្នែកនីតិវិធីនាពេលបច្ចុប្បន្ន។

---

២០១៩។ សូមមើលផងដែរ ឧបសម្ព័ន្ធ ១ និង ២ នៃការដាក់ឯកសារនេះ សម្រាប់ឯកសារជាភាសាខ្មែរ និងភាសាអង់គ្លេសនៃបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤។

ខ. បង្គាប់ថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទទួលបានសិទ្ធិចូលពិនិត្យមើលសំណុំរឿង នៅក្នុងដំណាក់កាលនេះ។

គ. បង្គាប់ថា ភាគីនានា អង្គជំនុំជម្រះ និងស្ថាប័នដទៃទៀតទាំងអស់របស់ អ.វ.ត.ក ត្រូវផ្ញើជូនទៅសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សំណុំរឿង០០៤/២[73] នូវការទំនាក់ទំនង និងការដាក់ឯកសារកន្លងមកទាំងអស់ ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធី សំណុំរឿង ០០៤/២ ដែលកន្លងមកមិនបានផ្ញើជូនពួកគាត់ រួមទាំងការដាក់ឯកសារ និងការទំនាក់ទំនងទៅអង្គជំនុំជម្រះសាលាដំបូង និង

ឃ. បង្គាប់ថា ចាប់ពីពេលនេះទៅ ភាគី អង្គជំនុំជម្រះ និងស្ថាប័នដទៃទៀតទាំងអស់របស់ អ.វ.ត.ក ត្រូវផ្ញើជូនទៅសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី នូវការទំនាក់ទំនង និងការដាក់ឯកសារទាំងអស់ ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធី សំណុំរឿង ០០៤/២ រហូតដល់ពេលដែល អ.វ.ត.ក បានប្រកាសទទួលស្គាល់ជាផ្លូវការចំពោះសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០៤/២។

សូម លោក លោកស្រី ចៅក្រមទទួលការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០ | ហុង គីមសួន | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០ | ឡោ ជុនធី | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០ | សំ សុគង់ | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |

[73] មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ និងអន្តរជាតិទាំងអស់ ដែលតំណាងឲ្យកូនក្តីក្នុងសំណុំរឿង ០០៤/២ គឺមានឈ្មោះនៅក្នុងផ្នែក "ដាក់ដោយ" និង "ផ្ញើជូន" នៃសារណានេះ។

| | | | |
|---|---|---|---|
| ថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០ | ស៊ិន ស៊ុរីន | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០ | Emmanuel JACOMY | ប្រទេសសិង្ហបុរី | |
| ថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០ | Martine JACQUIN | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០ | Daniel MCLAUGHLIN | San Francisco សហរដ្ឋអាមេរិក | |
| ថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០ | Nushin SARKARATI | San Francisco សហរដ្ឋអាមេរិក | |